# អ្នកនាំសារ
## The Messenger

36

ខែកក្កដា ឆ្នាំ២០០៦- ព័ត៌មានសម្រាប់ប្រើប្រាស់តែនៅក្នុងព្រះសហគមន៏កាតូលិកប៉ុណ្ណោះ



# ចូលរួមអភិរក្សសត្វព្រៃ



“ព្រះបន្ទូលនាំព្រះសហគមន៏ឱ្យរីកចម្រើន”

ទំព័រ ៦



ចុងឃ្មៀស : ព្រះសហគមន៏លើទឹក

ទំព័រ ១១

ស្វែងយល់អំពីព្រះសហគមន៏ទាំងអស់គ្នា

ទំព័រ ១២

# សំនួរក្មេងៗ

## ព្រះយេស៊ូរើសគ្រិស្តទូត


Photo: DR

នៅក្នុងលេខមុនៗ អ្នកនាំសារ បានលើកយកសំនួរផ្សេងៗ អំពីដំណើរជីវិតរបស់ព្រះយេស៊ូ តាំងពីប្រសូតរហូតដល់សោយទិវង្គត ហើយព្រះជាម្ចាស់បានប្រោសព្រះអង្គឱ្យមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង។ ពេលនេះ អ្នកនាំសារ មានសំនួរបន្ថែម ដើម្បីបង្ហាញប្អូនៗបន្តទៀតដូចខាងក្រោម :

**តើព្រះយេស៊ូមានសាវ័កប៉ុន្មាននាក់ ?**

តាមគម្ពីរ ព្រះយេស៊ូមានមនុស្សជាច្រើន ដែលដើរតាមព្រះអង្គទៅគ្រប់កន្លែងដើម្បីស្តាប់ការបង្រៀនរបស់ព្រះអង្គ ដែលខុសប្លែកពីអ្នកដទៃ។ ដូច្នេះឃើញថា សាវ័ករបស់ព្រះយេស៊ូគឺមានច្រើនណាស់។ ប៉ុន្តែព្រះយេស៊ូបានជ្រើសរើស ១២នាក់ ពីក្នុងចំណោមសាវ័កទាំងអស់ឱ្យធ្វើជាគ្រិស្តទូត។

**តើគ្រិស្តទូត ១២នាក់ មានឈ្មោះអ្វីខ្លះ ?**

មានដូចជា : លោកស៊ីម៉ូន ហៅពេត្រុស /សិលា និងលោកអន់ដ្រេជាប្អូនរបស់គាត់ លោកយ៉ាកុប និងលោកយ៉ូហានជាប្អូនគាត់ និងត្រូវជាកូនរបស់លោកសេបេដេ លោកភីលីព លោកបារថូឡូមេ លោកថូម៉ាស់ និងលោកម៉ាថាយជាអ្នកទារពន្ធ លោកយ៉ាកុបកូនលោកអាល់ផាយ លោកថាដេ លោកស៊ីម៉ូនជាអ្នកជាតិនិយម និងលោកយូដាសអ៊ីស្ការីយ៉ុតជាអ្នកក្បត់ព្រះយេស៊ូ។

**តើគ្រិស្តទូតទាំង១២នាក់នេះ ត្រូវធ្វើខ្លះ ?**

គឺត្រូវនៅជាមួយព្រះយេស៊ូគ្រប់ទីកន្លែង និងបន្តមុខងារដែលព្រះអង្គចាត់ឱ្យធ្វើ គឺប្រកាសដំណឹងល្អដល់មនុស្សគ្រប់រូប គ្រប់ជាតិសាសន៍នៅក្នុងពិភពលោកនេះឱ្យទៅជាសាវ័ក ព្រមទាំងប្រោសអ្នកជំងឺឱ្យជាសះស្បើយផងដែរ។ អ្នកទាំងអស់នេះហើយ បានកសាងព្រះសហគមន៍ឱ្យកើតមានឡើង ក្រោមការណែនាំរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។

លី សុវណ្ណា

# អធិប្បាយព្រះបន្ទូល

**ថ្ងៃទី ០៩ កក្កដា ២០០៦ ត្រូវនឹងអាទិត្យទី ១៤ ប្រចាំឆ្នាំ ខ**

## “គេមើលងាយព្យាការីតែក្នុងស្រុកកំណើត ក្នុងក្រុមគ្រួសារ និងក្នុងផ្ទះរបស់លោកប៉ុណ្ណោះ”

(ម៉ាកុស ៦,១-៦)

ជួនកាលយើងនឹកគិតថា បើខ្ញុំរស់នៅសម័យព្រះយេស៊ូ ឃើញលោកធ្វើការអស្ចារ្យ និងស្តាប់លោកមានប្រសាសន៍ប្រកបដោយប្រាជ្ញានោះ ខ្ញុំគង់តែជឿព្រះអង្គមិនខាន! ម្តេចក៏អ្នកស្រុកមិនជឿដូច្នេះ? តាមពិតព្រះយេស៊ូគង់ជាមួយយើងសព្វថ្ងៃ ព្រះអង្គក៏មានបន្ទូលមកយើង តាមរយៈមនុស្សទាំងប៉ុន្មានដែលយើងជួបរៀងរាល់ថ្ងៃ ប៉ុន្តែយើងមិនចាប់អារម្មណ៍ ធ្វើមិនដឹង មិនឮ ពីព្រោះយើងស្គាល់គេច្បាស់ពេក មិនព្រមស្តាប់គេទេ។ ព្យាការីគឺជាអ្នកនិយាយក្នុងនាមព្រះជាម្ចាស់ មិនជាមនុស្សធ្វើការអស្ចារ្យ អ្នកមានប្រាជ្ញា ឬអ្នកមានសំនួនវោហារទេ តែជាមនុស្សដែលរស់នៅជាមួយព្រះអង្គ និងនឹកគិតដល់ព្រះអង្គ ទោះបីជាគេជាអ្នកណាក្តី អ្នកមាន អ្នកក្រ អ្នកធំ ឬអ្នកតូចតាចក្តី។ កុំស្មានថា មានតែលោកអភិ-បាលបូជាចារ្យ គ្រូអប់រំជំនឿ ឬដូនជីប៉ុណ្ណោះ ដែលនិយាយក្នុងនាមព្រះជាម្ចាស់ មនុស្សគ្រប់ៗរូប សុទ្ធតែមានព្រះវិញ្ញាណព្រះអង្គគង់នៅជាមួយ ហើយអាចណែនាំយើងឱ្យស្គាល់សេចក្តីពិតបាន។



យើងត្រូវស្ងើចសរសើរ និងគោរពអ្នកដទៃ ទុកជារូបតំណាងនៃព្រះគ្រិស្តជានិច្ច។ យើងត្រូវបើកចិត្តគំនិតទទួលសេចក្តីពិតដែលមករកយើង តាមរបៀបផ្សេងៗគ្នា។ អ្នកធ្លាប់រួមរស់ជាមួយព្រះគ្រិស្ត អ្នកនោះពិតជាធ្លាប់មានបទពិសោធន៍ស្តាប់សម្លេងព្រះអង្គតាមរយៈអ្នកដទៃទៀតដែរ។

**ថ្ងៃទី ១៦ កក្កដា ២០០៦ ត្រូវនឹងអាទិត្យទី ១៥ ប្រចាំឆ្នាំ ខ**

## “កុំយកប្រាក់កាសជាប់នឹងខ្លួន”

(ម៉ាកុស ៦,៧-១៣)

ព្រះយេស៊ូចាត់សាវ័កពីរនាក់ម្តងៗ ព្រះអង្គចង់ឱ្យមនុស្សរួមបេសកកម្មរបស់ព្រះអង្គ ដោយចេញទៅប្រកាសថា ជីវិតយើងមានតម្លៃ យើងជាបុត្រធីតារបស់ព្រះបិតាគ្រប់ៗគ្នា ព្រះអង្គកំពុងគ្រងរាជ្យលើមនុស្សហើយ! ព្រះយេស៊ូប្រគល់ឱ្យគេមាននូវអំណាចដេញមារ គឺលុបបំបាត់សេចក្តីអាក្រក់គ្រប់យ៉ាងដែលជិះជាន់សង្កត់សង្កិនមនុស្សលោកឱ្យមានភាពល្ងង់ខ្លៅ ក្រីក្រ ជំងឺរោគា និងអយុត្តិធម៌ជាដើម។

ព្រះយេស៊ូក៏ចាត់យើងសព្វថ្ងៃដែរ។ ព្រះយេស៊ូចាត់គេពីរៗនាក់ ពីព្រោះតាមច្បាប់ស្រុកយូដា ត្រូវមានសាក្សីពីរនាក់ ទើបសក្ខីភាពរបស់គេអាចយកជាការបាន។ យើងធ្វើការរួមជាមួយព្រះអង្គ លុះត្រាតែយើងរួមជាមួយអ្នកដទៃដោយមានចិត្តស្រលាញ់។ អ្នកដែលប្រកាសជំនឿតែម្នាក់ឯង ប្រហែលធ្វើការអស្ចារ្យ តែគ្មានលទ្ធផលអ្វីនៅចំពោះព្រះជាម្ចាស់ឡើយ។

ព្រះអង្គបញ្ជាសាវ័កពីដើមកុំឱ្យយកអ្វីមកជាមួយនៅតាមផ្លូវ គឺត្រូវធ្វើជីវិតទាំងស្រុង និងថ្វាយការងារខ្លួនទៅលើឫទ្ធានុភាពព្រះអង្គ។ យើងគឺជាអ្នកសាបព្រោះ តែមានតែព្រះជាម្ចាស់ទេ ដែលធ្វើឱ្យពូជដុះឡើងបាន។ តាមផ្លូវវិញ្ញាណ យើងបង្កើតផលបាន ពុំមែនមកពីយើងមានប្រាជ្ញាចេះថ្លែងពាក្យសំដីគួរឱ្យចាប់អារម្មណ៍ មានធនធានចែកចាយគេ ឬមានចំណេះដឹងឡើយ គឺព្រះគ្រិស្តទេ ដែលមានព្រះបន្ទូលតាមយើង ព្រះអង្គប្រោសកិច្ចការយើងឱ្យបានផល។ បើយើងចង់ប្រកាស ដំណឹងល្អ រួមជាមួយព្រះយេស៊ូ យើងត្រូវលះបង់អ្វីៗទាំងអស់ និងរួមចិត្តគំនិតដោយស្មោះជាមួយព្រះអង្គវិញ។





**ថ្ងៃទី ២៣ កក្កដា ២០០៦ ត្រូវនឹងអាទិត្យទី ១៦ ប្រចាំឆ្នាំ ខ**

## “ព្រះយេស៊ូនឹកអាណិតអាសូរមហាជន ទើបព្រះអង្គបង្រៀនគេយ៉ាងយូរ”

(ម៉ាកុស ៦,៣០-៣៤)

សព្វថ្ងៃព្រះយេស៊ូចាត់យើងឱ្យប្រកាសដំណឹងល្អ ដល់ជនជាតិកម្ពុជាថា ជីវិតមានតម្លៃ មនុស្សគ្រប់ៗរូបសុទ្ធតែជាបុត្រធីតានៃព្រះបិតា។ ព្រះអង្គមិនចាត់យើងឱ្យប្រមែប្រមូលមនុស្ស ដើម្បីឱ្យព្រះសហគមន៍ចម្រើនធំឡើង ឱ្យព្រះសហគមន៍មានចំនួនច្រើន ឬមានអំណាចឡើយ។ ព្រះអង្គចាត់យើងពីព្រោះព្រះអង្គមានព្រះហឫទ័យអាណិតអាសូរដល់គេ។ គួរឱ្យឆ្ងល់ណាស់នៅពេលអ្នកស្រុកមករកព្រះយេស៊ូ ព្រះអង្គមិនបានប្រទានអាហារ ឬលុយឱ្យគេទេ ព្រះអង្គបង្រៀនគេទៅវិញ។ ព្រះបន្ទូលនេះពិតជាអាហារដែលធ្វើឱ្យគេបានស្កប់ចិត្ត ជាជាងបានលុយកាក់ទៅទៀត។

ជួនកាលបងប្អូនកម្ពុជាស្មានថា ព្រះសហគមន៍ជាអង្គការមនុស្សធម៌ដូចគេឯងដែរ។ គេមកពឹងលើព្រះសហគមន៍ដើម្បីរកប្រយោជន៍ផ្ទាល់ខ្លួន។ យើងត្រូវមានចិត្តអាណិតអាសូរដូចព្រះយេស៊ូដែរ គឺមើលនូវសេចក្តីត្រូវការ តាមផ្លូវចិត្តរបស់គេ កុំរកតែផ្គត់ផ្គង់ តាមផ្លូវលោកប៉ុណ្ណោះ។ មុខងារនៃព្រះសហគមន៍គឺបង្ហាញទិសឆ្ពោះទៅកាន់សុភមង្គលដ៏ពិតប្រាកដ នោះគឺតម្លៃដ៏ពិតប្រាកដរបស់ជីវិតគេ។ ការជួយគេតាមផ្លូវលោកជាការល្អ ដែលបញ្ជាក់ពីចិត្តគំនិតរបស់យើង ប៉ុន្តែមុខងាររបស់សាវ័កព្រះយេស៊ូ គឺសម្តែងអំពីទិសដៅនៃជីវិតរស់នៅដ៏ពេញលេញវិញ។



**ថ្ងៃទី ៣០ កក្កដា ២០០៦ ត្រូវនឹងអាទិត្យទី ១៧ ប្រចាំឆ្នាំ ខ**

## “លោកពិតជាព្យាការីដែលត្រូវមកក្នុងពិភពលោក”

(យ៉ូហាន ៦,១-១៥)

មនុស្សម្នាមករកព្រះយេស៊ូដោយមានបំណងស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន គេចង់បាន និងចង់ឱ្យព្រះអង្គប្រោសគេគ្រប់បែបយ៉ាង។ ព្រះអង្គយកចិត្តទុកដាក់នឹងបំណងរបស់គេ តែព្រះអង្គសូមឱ្យអ្នកដទៃជួយចិញ្ចឹមគេដែរ។ ព្រះអង្គមិនប្រព្រឹត្តការអស្ចារ្យតែមួយព្រះអង្គឯង គឺសូមលោកភីលីពគិតគូរ ព្រះអង្គយកត្រី និងអាហារដ៏តិចតួចរបស់ក្មេងម្នាក់មកចែកគេ។ សូមសាវ័កទាំងដប់ពីរជួយរៀបចំបណ្តាជនឱ្យមានរបៀបរៀបរយ រួចប្រមែប្រមូលចំណិតដែលនៅសល់។

សព្វថ្ងៃនៅប្រទេសកម្ពុជា មានមនុស្សជាច្រើនខ្វះសេចក្តីដែលត្រូវការជាចាំបាច់ប្រចាំជីវិត។ ប្រសិនបើយើងរួមគ្នាដូចជាសាវ័ករបស់ព្រះយេស៊ូ គង់តែសភាពការណ៍នឹងចម្រើនឡើងមិនខាន។ គ្រិស្តបរិស័ទជាច្រើនតែងតែគិតដល់ខ្លួនឯង មុនគិតដល់អ្នកដទៃឯទៀត។ ចំណែកឯព្រះយេស៊ូវិញ ព្រះអង្គសូមឱ្យយើងគិតដល់អ្នកដទៃ មុននឹងគិតដល់ខ្លួនឯង។

សូម្បីតែគ្រិស្តបរិស័ទដែលធ្វើការងារនៅអង្គការមនុស្សធម៌ ក៏កេងប្រវ័ញ្ចបន្លំវិក្កយបត្រដែរ។ល។ គេថា គេស្អប់ពុករលួយ តែគេធ្វើដូចអ្នកដទៃដែរ។ បើធ្វើដូច្នេះ យុត្តិធម៌នឹងមិនអាចកើតមានឡើងនៅក្នុងប្រទេសកម្ពុជាឡើយ។



សូមព្រះយេស៊ូជាអម្ចាស់ ដែលបានបូជាព្រះជន្មសម្រាប់អ្នកដទៃជួយដល់យើងឱ្យសុខចិត្តគិតដល់អ្នកដទៃ មុនគិតដល់ប្រយោជន៍ផ្ទាល់ខ្លួន។

**សូមថ្លែងអំណរគុណចំពោះជំនួយនៃក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា!**



## សាក្សីដ៏ស្មោះត្រង់ !

បងប្អូនជាទីស្រលាញ់ ! យើងទាំងអស់មានសំណាងដែលបានទទួលអំណោយទានយ៉ាងប្រសើរពីព្រះជាម្ចាស់ ជាពិសេសយើងបានទទួលព្រះជន្មផ្ទាល់របស់ព្រះយេស៊ូ ដោយអគ្គសញ្ញាជ្រមុជទឹក ដែលយើងបានស្ម័គ្ររួមស្លាប់រួមរស់ជាមួយព្រះយេស៊ូគ្រិស្ត ដែលជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះអម្ចាស់នៃយើងទាំងអស់គ្នា។

ព្រះយេស៊ូយាងមកក្នុងពិភពលោកយើងនេះ ដើម្បីបង្ហាញឱ្យយើងស្គាល់នូវធម៌មេត្តាករុណា និងសេចក្តីស្រលាញ់ដ៏លើសលប់របស់ព្រះបិតាចំពោះយើងរហូតដល់ព្រះអង្គបូជាព្រះជន្មនៅលើឈើឆ្កាង។

ព្រះយេស៊ូជាសាក្សីដ៏ពិតប្រាកដ ដែលបានប្រាប់ដល់យើងនូវអ្វីដែលព្រះអង្គមើលឃើញ និងបានឮពីព្រះបិតាមក។ ក្រោយពីព្រះជាម្ចាស់បានប្រោសព្រះអង្គ ឱ្យមានព្រះជន្មរស់ឡើងវិញដ៏រុងរឿង មានសាវ័កជាច្រើនដែលបានស្ម័គ្របន្តប្រកាសដំណឹងល្អ អំពីសេចក្តីស្រលាញ់តាមគំរូរបស់ព្រះយេស៊ូរហូតត្រូវគេធ្វើបាប និងត្រូវគេសម្លាប់ជាបន្តបន្ទាប់។ ដោយសារការលះបង់របស់បងប្អូនទាំងនោះ ទើបយើងបានស្គាល់ព្រះយេស៊ូនៅថ្ងៃនេះ។ ព្រះសហគមន៍នៅកម្ពុជាក៏មានបងប្អូនដែលបានខិតខំរក្សាជំនឿរបស់ខ្លួនរហូតដល់បូជាជីវិតថ្វាយព្រះយេស៊ូ ក្នុងសម័យសង្គ្រាម ដែលរួមមានលោកអភិបាលភូមិ-ភាគបាត់ដំបង លោកអភិបាលភូមិភាគភ្នំពេញ លោកបូជាចារ្យ ព្រមទាំងគ្រិស្តបរិស័ទខ្មែរជាច្រើនរូប។ ចំពោះបងប្អូននៅរស់ក៏ខិតខំរក្សា និងបន្តជំនឿដល់បងប្អូនដែលចង់ស្គាល់ព្រះយេស៊ូផងដែរ។

តើខ្ញុំគួរប្រព្រឹត្តខ្លួនរបៀបយ៉ាងណាដើម្បីឱ្យក្លាយជាសាក្សីអំពីសេចក្តីស្រលាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះជាម្ចាស់ ?

អ្នកនាំសារ

## គោរពព្រះកាយ និងព្រះលោហិត


Photo: Savène

កាលពីថ្ងៃអាទិត្យទី២៨ ខែមិថុនា ឆ្នាំ២០០៦ នៅព្រះសហគមន៏បាត់ដំបង មានរៀបចំពិធីបុណ្យគោរពព្រះកាយ និងព្រះលោហិតព្រះគ្រិស្ត។
កម្មវិធីនេះរៀបចំដោយក្រុមគណៈកម្មការរៀបចំបុណ្យព្រះសហគមន៏ ព្រមទាំងក្រុមយុវជន។ ពិធីមានការចូលរួមពីបងប្អូនគ្រិស្តបរិស័ទប្រមាណជា ៣០០នាក់ ព្រមទាំងលោកអភិបាលគីកេ លោកឪពុកពេជ្រ និងលោកឪពុកហ្គាប៊ីក។ ក្នុងឱកាសនោះផងដែរ មានបងប្អូនមកពីព្រះសហគមន៏បាត់ដំបងចំនួន ២៨នាក់ បានទទួលអគ្គសញ្ញាទទួលព្រះកាយលើកដំបូង។ អត្ថន័យនៃបុណ្យថ្ងៃនេះ គឺលើកតម្កើងព្រះអង្គដែលបានបូជាជីវិតដើម្បីសង្គ្រោះយើងទាំងអស់គ្នាឱ្យរួចពីបាប។ សុ ជាតិ

## ពិធីសម្ពោធស្រះទឹក និងអគារសិក្សា


Photo: DR

នាព្រឹកថ្ងៃព្រហស្បតិ៍ទី២២ ខែមិថុនា ឆ្នាំ២០០៦ នៅភូមិត្រពាំងក្បាលស្វា និងព្រៃធំ ឃុំក្តុលតាហែន ស្រុកបវេល ខេត្តបាត់ដំបង មានប្រារព្ធធ្វើពិធីសម្ពោធបើកឱ្យប្រើប្រាស់នូវសមិទ្ធផលអគារសិក្សាមួយខ្នង ប្រាំបន្ទប់ និងស្រះទឹកមួយ ដែលជាអំណោយនៃអង្គការសៅសេតាមរយៈមណ្ឌលស្វាគមន៏ជនពិការ "អារ៉ូប៉េករុណា" ក្នុងនាមព្រះសហគមន៏កាតូលិក នៅក្រោមអធិបតីភាពរបស់ឯកឧត្តមប្រាជ្ញ ចន្ទ អភិបាលខេត្តបាត់ដំបង លោកអភិបាលគីកេ អភិបាលស្រុកបវេល តំណាងអង្គការជាតិ និងអន្តរជាតិ បងប្អូនប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សប្រមាណជាង ៨០០នាក់។ នៅក្នុងនោះដែរក៏មានប្រគល់នូវបណ្ណសរសើរជូនលោកអភិបាលគីកេ ដែលលោកបានខិតខំជួយអំពាវនាវរកជំនួយពីបរទេស តាមរយៈអង្គការសៅសេ ដែល [illegible] សុ ជាតិ


## អេម៉ានូអែល សម្លេងពីព្រះសហគមន៏កាតូលិក

បាត់ដំបង: FM 91.0 Mhz
ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍។

ភ្នំពេញ: FM 99.5 Mhz
ម៉ោង ៧:០០-៧:៣០ រាល់ល្ងាចថ្ងៃសៅរ៍។


## ខ្ញុំវិលមកវិញ!


Photo: L. Sovanna

នាថ្ងៃទី០២ កក្កដា កន្លងទៅនេះ លោកបូជាចារ្យ អូមែរ ហ្គីរាល់ដូ ជាប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៏កាតូលិក (CSC) បានវិលត្រលប់មកកាន់ប្រទេសកម្ពុជាវិញហើយ។ លោកបានចាកចេញពីប្រទេសកម្ពុជារយៈពេលប្រហែលមួយឆ្នាំ ដើម្បីទៅជួបជុំឪពុកម្តាយនៅប្រទេសកូឡុំប៊ី ជាស្រុកកំណើតលោក។ លោកវិលមកនេះគឺដើម្បីធ្វើការជាមួយបងប្អូន និងបម្រើព្រះសហគមន៏កាតូលិកនៅកម្ពុជាយើងតទៅទៀត។

## ដំណើរទស្សនកិច្ចរបស់យុវជន YRDP

មានដំណើរទស្សនកិច្ចជាលើក ទី២ របស់ក្រុមយុវជននៃអង្គការវ៉ាយអរឌីភី (YRDP) ដែលមានឈ្មោះពេញ ជាភាសាខ្មែរថា : "កម្មវិធីអភិវឌ្ឍន៏ធនធានយុវជន" មកកាន់ព្រះសហគមន៏កាតូលិកផ្សារតូចក្នុងគោលដៅស្គាល់អំពីការអនុវត្តរបៀបផ្សេងៗដែលមាននៅក្នុងព្រះសហគមន៏កាតូលិក នៅកម្ពុជា។ ក្រុមយុវជន YRDP នេះ គឺជាក្រុមដែលសិក្សា ពីអន្តរជំនឿសាសនានៅក្នុងប្រទេសកម្ពុជា។
កម្មវិធីនេះបានធ្វើឡើងកាលពីថ្ងៃទី២៤ មិថុនា ២០០៦កន្លងទៅនេះ ដែលមានការចូលរួមអំពីសំណាក់គ្រិស្តបរិស័ទកាតូលិក និងប្រូតេស្តង់ ឥស្លាមបរិស័ទ និងពុទ្ធបរិស័ទ ដែលរួមមានព្រះសង្ឃ៣អង្គ និងសរុបទាំងអស់មានមនុស្ស [illegible] កញ្ញា


Photo: Vutha





## ជីវិតគ្រិស្តបរិស័ទនៅលើទឹក

យ៉ាងហោចណាស់ ក៏មានប្រជាជនប្រមាណជាង ៥០០០គ្រួសារ កំពុងរស់នៅលើទឹក ក្នុងនោះ ជាង២០០នាក់ ជាគ្រិស្តបរិស័ទនៅឃុំកំពង់ហ្លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលមានចំងាយ ១៥០គម ពីទីក្រុងភ្នំពេញ។ ជីវភាពរស់នៅលើទឹក គឺមានការលំបាកយ៉ាងខ្លាំង ដោយសារមានការខ្វះខាតច្រើន ដូចជាទឹកស្អាតជាដើម ទោះបីជាប្រជាជនរស់នៅលើទឹកក៏ដោយ។
អ្នកស្រីលី ណាម អាយុ៥៣ឆ្នាំ ជនជាតិវៀតណាម ជាគណៈកម្មការព្រះសហគមន៏កំពង់ហ្លួង និងជាអ្នកលក់ការ៉េមផងនោះ មានប្រសាសន៏ថា : "រូបខ្ញុំព្រមទាំងគ្រិស្តបរិស័ទ ដែលរស់នៅក្នុងទន្លេនេះ មានជីវភាពលំបាក ព្រោះពេលទឹកទន្លេឡើង ខ្ញុំរកត្រីមិនបានទេ"។ សំដីនិយាយខ្មែរមិនសូវច្បាស់ គាត់បន្តថា : "ពិតមែន តែយើងរស់នៅក្នុងទន្លេ ប៉ុន្តែយើងគ្មានទឹកប្រើប្រាស់គ្រប់គ្រាន់ទេ គឺយើងត្រូវដងទឹកមិនស្អាតនៅជុំវិញផ្ទះយកមកកូរសាច់ជូរដើម្បីប្រើប្រាស់"។


Photo: H. Sokhteary
ទិដ្ឋភាពទូទៅនៃឃុំកំពង់ហ្លួង

លោកបូជាចារ្យទម្លាប់ សុផល ភ្នែកកំពុងសម្លឹងផ្ទៃទឹក ប្រាប់ថា : "មានម្តងខ្ញុំមកទីនេះនៅរដូវប្រាំង ជុំវិញពោរពេញដោយទឹកដែលមានស្លែ ឃើញគេវាយទឹកកក ដាក់កែវ រួចដួសទឹកដែលនៅមុខផ្ទះរបស់គេ ហើយផឹកតែម្តង"។ ហ៊ូ សុខធារី

## ជំនួបដើម្បីការងាររីកចម្រើន


Photo: Fr. Evan
ប្រធានក្រុមយុវជនជួបគ្នាប្រជុំ

នៅព្រះសហគមន៏ក្រុងកំពង់ចាម កាលពីថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៦កន្លងទៅនេះ មានជំនួបគ្នាមួយរវាងប្រធាននៃក្រុមយុវជនទាំងអស់ក្នុងភូមិភាគកំពង់ចាម ដែលមានអ្នកចូលរួមប្រមាណជា ៤២នាក់។
ជំនួបនេះគឺធ្វើឡើងដើម្បីចែករំលែកបទពិសោធន៏ និងស្វែងយល់ពីយុទ្ធសាស្ត្រលើប្រធានបទ: "លក្ខណៈនៃអ្នកណែនាំ"។ នាឱកាសនោះដែរ ក៏មានការចូលរួមពីលោកអន់តូនី អភិបាលភូមិភាគកំពង់ចាម លោកបូជាចារ្យ [illegible]។ រ៉ូ បូរ៉ា

## ពិធីសម្ពោធព្រះវិហារព្រៃកស្បូវ

កាលពីថ្ងៃទី១១ មិថុនា ២០០៦ កន្លងទៅនេះ នៅព្រះសហគមន៏ព្រៃកស្បូវ ខេត្តកំពង់ធំ ភូមិភាគបាត់ដំបង មានការរៀបចំពិធីសម្ពោធព្រះវិហារថ្មីមួយធ្វើអំពីថ្ម និងឈើ ដែលបានមកពីការឧបត្ថម្ភរបស់សម្តេចប៉ាបបេណេឌីកទី១៦ គ្រិស្តបរិស័ទនៃប្រទេសជប៉ុន និងការរៃអង្គាសពីបងប្អូនគ្រិស្តបរិស័ទ បងប្អូនពុទ្ធបរិស័ទ ក្នុងភូមិព្រៃកស្បូវ ដែលសរុបបានជាថវិកា ចំនួន ១៣៣០៣ ដុល្លារអាម៉េរិក។
ពិធីនេះបានប្រារព្ធធ្វើ ក្រោមអធិបតីភាពរបស់លោកអភិបាលគីកេ គ្រិស្តបរិស័ទមកពីព្រះសហគមន៏នានា ព្រមទាំងពុទ្ធបរិស័ទ នៅក្នុងភូមិព្រៃកស្បូវទាំងចាស់ ទាំងក្មេងមកចូលរួមយ៉ាងច្រើនកុះករ។ តាមប្រសាសន៏លោកបូជាចារ្យ ង៉ែត វិន័យ ជាអ្នកទទួលខុសត្រូវព្រះសហគមន៏ ព្រៃកស្បូវ បានឱ្យដឹងថា : "តាមពិត ខ្ញុំគិតថា មិនចង់ឱ្យមានព្រះវិហារទៀតទេ ដោយសារ នៅជិតភូមិព្រៃកស្បូវ មានព្រះវិហារធំមួយ គឺនៅកំពង់រទេះរួចហើយ ប៉ុន្តែគ្រិស្តបរិស័ទនៅទីនោះ គេមិនព្រម ដោយសំអាងថាក្រោយពីរបបប្រល័យពូជសាសន៏ ព្រះសហគមន៏ដែលកើតមុនគេនៅខេត្តកំពង់ធំ គឺព្រះសហគមន៏ព្រៃកស្បូវនេះ។ បើចង់ឱ្យគេទៅកាន់ព្រះសហគមន៏ផ្សេងទៀតនោះ គេប្រកែកមិនព្រមទៅទេ ដោយសារតែមូលហេតុទាំងនេះហើយ បានជាឆ្នាំនេះ មានព្រះវិហារថ្មីនៅទីនេះ"។
លោក បានបន្តទៀតថា រយៈពេលបីឆ្នាំកន្លងមក នៅព្រះសហគមន៏ នេះ បងប្អូនគ្រិស្តបរិស័ទ និងពុទ្ធបរិស័ទនៅទីនេះ គេនាំគ្នារៃអង្គាសប្រាក់មួយគ្រួសារៗ ខ្លះ ៥០០០រៀល ខ្លះ ១០០០០រៀល ខ្លះ ២០០០០ រៀល ទៅតាមលទ្ធភាពគ្រួសារនីមួយៗ មិនតែប៉ុណ្ណោះពួកគេបានចូលរួមជួយជាកម្លាំង ដូចជាជួយចាក់ដីធ្វើឈឿនព្រះវិហារ និងលាងក្បឿង [illegible] កែវ កញ្ញា


Photo: L. Sovanna
ព្រះវិហារថ្មីនៅព្រះសហគមន៏ព្រៃកស្បូវ

# លោកសុផល : “ព្រះបន្ទូលនាំដំណើរជីវិតព្រះសហគមន៍ឱ្យរីកចម្រើន”



លោកឪពុកសិលាទម្លាប់ សុផល

Photo: M. Kunthear

**ព្រះសហគមន៍នៅកម្ពុជានឹងរៀបចំអង្គសន្និបាតទូទាំងប្រទេសពីថ្ងៃទី១១-១៤ កក្កដា នៅព្រះវិហារសន្តយ៉ូសែបភ្នំពេញ ដោយមានបងប្អូនតំណាងព្រះស-ហគមន៍ទាំងបីភូមិភាគចំនួន១១០នាក់ ចូលរួម។ អ្នកនាំសារ ធ្វើសម្ភាសន៍ជាមួយលោកបូជាចារ្យសិលាទម្លាប់ សុផល សមាជិកក្រុមប្រឹក្សាសន្និបាត។**

**អ្នកនាំសារ :** លោកឪពុក ! ឮថានៅឆ្នាំនេះមានការរៀបចំសន្និបាតដែលនឹងនិយាយអំពីប្រវត្តិព្រះសហគមន៍នៅប្រទេសកម្ពុជាមែនទេ ?

**លោកបូជាចារ្យ :** រៀងរាល់ឆ្នាំបុរីវ៉ាទីកង់ បានសំណូមពរនូវប្រធានបទមួយដល់ព្រះសហគមន៍។ ឆ្នាំមុនគឺជាឆ្នាំលើកតម្កើងព្រះកាយព្រះគ្រិស្ត ហើយឆ្នាំនេះគឺជាឆ្នាំលើកតម្កើងព្រះបន្ទូល គួបផ្សំជាមួយព្រះសហគមន៍ នៅប្រទេសកម្ពុជារំលឹកខួប៤៥០ឆ្នាំ យើងភ្ជាប់ទាំង២នេះ បញ្ចូលគ្នា ជាប្រធានបទមួយព្រោះព្រះសហគមន៍កើតឡើងក្រោមពន្លឺរបស់ព្រះបន្ទូល ដែលមានព្រះវិញ្ញាណនាំ។ ប៉ុន្តែក្នុងការរីកចម្រើនរបស់ព្រះសហគមន៍ តែងមានអ្នកស៊ូប្តូរជីវិត លើព្រះយេស៊ូដូច្នេះ ជាប់នឹងមរណៈសាក្សី។ ហេតុនេះនៅក្នុងព្រឹត្តិការណ៍ដែលយើងឃើញដូចជាផ្លូវងងឹតសម្រាប់យើង ដូចជាមានគេមិនទទួលដំណឹងល្អ គេចង់សម្លាប់គ្រិស្តទូត ឬមរណៈសាក្សីខ្លះ ដែលបណ្តាលឱ្យព្រះសហគមន៍ខ្ចាត់ខ្ចាយ ប៉ុន្តែការខ្ចាត់ខ្ចាយនេះនាំឱ្យព្រះសហគមន៍រីកចម្រើនឡើង។ ជាងស្តែងនៅកម្ពុជាក្រោយសង្គ្រាម ព្រះសហគមន៍បែកចេញជាច្រើនកន្លែងដែលយើងមិនអាចយល់បានអស់សេចក្តី។

**អ្នកនាំសារ :** អ៊ីចឹងប្រធានបទនៃសន្និបាតគឺអ្វី ?

**លោកបូជាចារ្យ :** “ព្រះបន្ទូលដែលនាំដំណើរជីវិតព្រះស-ហគមន៍ឱ្យរីកចម្រើនឡើង” និងភ្ជាប់ទៅនឹងខួបទី ៤៥០ឆ្នាំនៃព្រះសហគមន៍នៅកម្ពុជាផងដែរ។

**អ្នកនាំសារ :** តើនឹងប្រព្រឹត្តទៅយ៉ាងណាដែរ ?

**លោកបូជាចារ្យ :** ថ្ងៃទី១ : លោកបូជាចារ្យហ្វ្រង់ស្វ័រ ប៉ុងសូដ៍ នឹងពន្យល់អំពីព្រះបន្ទូលដែលបំភ្លឺ និងនាំឱ្យព្រះសហ-គមន៍កើតឡើងបន្តិចម្តងៗ អំពី “ព្រះសហគមន៍ដើមដំបូង” និងអំពីរបៀបដំណឹងល្អចូលមកស្រុកខ្មែរ។ ថ្ងៃទី២ : ភូមិភាគភ្នំពេញ ដឹកនាំឱ្យស្គាល់ពីទីតាំងប្រវត្តិព្រះសហគមន៍ ដែលបានកើតឡើងនៅក្នុងស្រុកខ្មែរ។ ថ្ងៃទី៣ : ភូមិភាគកំពង់ចាម ជាអ្នករំឭកឱ្យដឹងអំពីប្រវត្តិព្រះសហគមន៍នីមួយៗក្នុងភូមិភាគទាំងបី។ និងថ្ងៃទី៤ : ភូមិភាគបាត់ដំបងជួយរិះគិតពីអត្ថន័យខាងព្រះវិញ្ញាណ ហើយមើលពីសភាពការណ៍ជាក់ស្តែងក្នុងសង្គមខ្មែរ ដូចជា ឥទ្ធិពលណាខ្លះដែលជាឧបសគ្គរបស់ព្រះសហគមន៍។ រកវិធានការយុទ្ធសាស្ត្រ ឬក៏វិធីសាស្ត្រណាខ្លះ ដើម្បីយកទៅដោះស្រាយបញ្ហា។

**អ្នកនាំសារ :** អ៊ីចឹងគ្រាន់តែលើកយកបញ្ហាយកមករិះគិតរួមគ្នាតែប៉ុណ្ណោះឬ ?

**លោកបូជាចារ្យ :** បាទ! នេះគឺអង្គសន្និបាតសម្រេចរួមគ្នាដែរ។ ព្រះសហគមន៍ទាំងអស់យកអ្វីដែលអង្គសន្និបាតបានសម្រេច គឺមួយណាដែលធ្ងន់ មួយណាដែលជាចំនុចក្តៅ ដែលជាផលប៉ះពាល់យកទៅសាកល្បងអនុវត្តនៅក្នុងព្រះសហគមន៍។

**អ្នកនាំសារ :** រហូតមកដល់ពេលនេះ យើងបានមើលឃើញនូវបញ្ហារបស់ព្រះសហ-គមន៍ណាមួយដែរឬយ៉ាងណា ?

**លោកបូជាចារ្យ :** បើនិយាយអំពីសេដ្ឋកិច្ចរបស់ព្រះសហគមន៍ នៅក្នុងភូមិភាគបាត់ដំបង . . .



រូបថតអនុស្សាវរីយ៍ ព្រះសហគមន៍ថ្មីនៅថ្មពេជ្រ ភូមិភាគកំពង់ចាម

Photo: L. Sovanna

. . . ពោលគឺ នៅតំបន់ទន្លេ រវាងខែនេសាទ គឺមានចាស់ជរាខ្លះ និងកូនក្មេងខ្លះៗប៉ុណ្ណោះ ដែលនៅផ្ទះ ទោះបីយើងចង់បង្រៀនអក្សរសាស្ត្រខ្មែរដល់យុវវ័យ ក៏គ្មានឱកាសដែរ។ ចំណែកឯនៅតំបន់ខាងលិច ភាគច្រើន គេទៅស្រុកថៃដើម្បីធ្វើការ។ ក្រៅពីនេះ យើងក៏មានការប្រកាន់ពូជសាសន៍រវាង បងប្អូនខ្មែរ និងវៀតណាម គឺជាចំនុចដែលយើងត្រូវតស៊ូព្យាយាមរួបរួមគ្នាទាំងសងខាង។ បញ្ហាសិក្សា ក៏ជាចំនុចក្តៅមួយដែរដែលជះឥទ្ធិពលអាក្រក់ដែរជាពិសេសព្រះសហគមន៍នៅជនបទ រីកចម្រើនពិបាកដោយជនភាគច្រើនមិនចេះអក្សរ។

**អ្នកនាំសារ :** ឃើញបញ្ហាហើយ តើក្នុងអង្គសន្និបាតនឹងមានការជំរុញឱ្យមានការបង្កើតគណៈកម្មការដើម្បីធ្វើកិច្ចការនេះដែរឬទេ ?

**លោកបូជាចារ្យ :** នេះគឺវាអាស្រ័យទៅលើអង្គសន្និបាត។ ប៉ុន្តែ យើងមិនទាន់មានគំនិតដើម្បីបង្កើតគណៈកម្មការមួយក្នុងការដោះស្រាយបញ្ហាទេ។

**អ្នកនាំសារ :** តើនឹងមានការជ្រើសរើសព្រះសហគមន៍ណាមួយដើម្បីធ្វើការអនុវត្តសាកល្បងដែរឬទេ ?

**លោកបូជាចារ្យ :** អត់ទេ! យើងមិនទៅដល់ទិសដៅនោះទេ ប៉ុន្តែសម្រាប់ព្រះសហគមន៍ទាំងអស់គឺអង្គសន្និបាតដែលជាអ្នកធ្វើការសម្រេច។ម្យ៉ាងទៀតយើងចង់ឱ្យអង្គសន្និបាតស្គាល់ព្រះសហគមន៍បច្ចុប្បន្ន ទាំងបីភូមិភាគ។ យើងនឹងធ្វើសៀវភៅមួយ គឺព្រះសហគមន៍នីមួយៗ ១សន្លឹក (២ទំព័រ) ដោយម្ខាងជាទំព័រអំពីសកម្មភាពព្រះសហគមន៍សព្វថ្ងៃ និងម្ខាងទៀតជាប្រវត្តិពីដើម។

**អ្នកនាំសារ :** តើអង្គសន្និបាតនេះនឹងផ្តល់នូវសារៈសំខាន់យ៉ាងណាខ្លះ ?

**លោកបូជាចារ្យ :** ទី១ ពង្រឹងជំនឿរបស់បងប្អូន គឺជួយឱ្យយល់ពីតម្លៃ និងអត្ថន័យនៃឧបសគ្គនីមួយៗ វាពុំធ្វើឱ្យយើងបោះបង់ជំនឿនោះទេ ប៉ុន្តែវាគឺជាឱកាសជួយពង្រឹងទឹកចិត្តយើង និងរវាងសេចក្តីស្រលាញ់ដែលព្រះអម្ចាស់មានចំពោះយើង និងសេចក្តីស្រលាញ់របស់យើង មានសម្រាប់ព្រះអង្គវិញ។ ទី២ គឺជួយឱ្យបងប្អូនដែលមិនធ្លាប់ធ្វើដំណើរឱ្យស្គាល់អំពីភូមិភាគផ្សេងៗ និងស្គាល់ពីវត្តមានព្រះសហគមន៍ដែលមាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អត្ថបទដោយលី សុវណ្ណា



វិសាលវិហារកាតូលិកនៅភ្នំពេញមុខទសវត្សរ៍ទី៧០

Photo: DR

## ប្រវត្តិព្រះសហគមន៍ដោយសង្ខេប

ដំណឹងល្អ បានចូលមកដល់ប្រទេសកម្ពុជាក្នុងអំឡុងសតវត្សរ៍ទី១៦ គឺឆ្នាំ ១៥៥៥ ក្នុងសម័យលង្វែកនៃរជ្ជកាលព្រះបាទអង្គចន្ទ ដោយសារបព្វជិត ជនជាតិព័រទុយហ្គាលម្នាក់ ឈ្មោះថាកាល្ស៉ាដាគ្រុស។ នៅឆ្នាំ១៥៧៤ លោកស៊ីលវេស ដាសេរេរ៉ូ ដែលជាបព្វជិតព័រទុយហ្គាលដែរ បានមកដល់ប្រទេសកម្ពុជា។ លោកគឺជាអ្នកដែលបានសាងសង់ព្រះវិហារកាតូលិកមុនគេ និងបានតែងសៀវភៅគ្រិស្តសាសនាមកជាភាសាខ្មែរផងដែរ។

នៅសតវត្សរ៍ទី១៧ គ្រិស្តបរិស័ទជាតិជប៉ុន បានមកតាំងទីលំនៅក្នុងស្រុកពញាឮ។ នៅឆ្នាំ១៦៦០ ក៏មានគ្រិស្តបរិស័ទជាតិឥណ្ឌូនេស៊ី ភៀសខ្លួនមកតាំងទីនៅនៅភ្នំពេញ និងស្រុកពញាឮ។

នៅក្នុងសតវត្សរ៍ទី១៨ មានគ្រិស្តបរិស័ទខ្លះនៅកំពង់ធំ។ ដោយសារសង្គ្រាមឈ្លានពាន ឆ្នាំ១៧៨៤ ពួកឧទ្ទាមវៀតណាមបំផ្លាញព្រះសហគមន៍ ហើយកៀរគ្រិស្តបរិស័ទខ្មែរភាគច្រើននៅកម្ពុជាក្រោម។ នៅឆ្នាំ១៧៨៥ ពួកឧទ្ទាមសៀមក៏កៀរគ្រិស្តបរិស័ទខ្មែរទៅបាងកក។ ប៉ុន្តែមានគ្រិស្តបរិស័ទខ្លះរត់រួច។ នៅថ្ងៃទី៥ មករា ឆ្នាំ១៧៩០ ពួកគេក៏មកតាំងនៅបាត់ដំបង។

នៅសតវត្សរ៍ទី ១៩ ប្រទេសជាតិជួបសង្គ្រាម។ នាឆ្នាំ១៨៦៦ ព្រះបាទនរោត្តមឱ្យគ្រិស្តបរិស័ទចាកចេញពីស្រុកពញាឮមកតាំងលំនៅនៅភ្នំពេញវិញ។ ព្រះរាជាចែកដីឱ្យគ្រិស្តបរិស័ទសាងសង់ព្រះវិហារនៅព្រែកលួង។

នៅថ្ងៃទី ២៦ កញ្ញា ឆ្នាំ១៩៦៨ ព្រះអសនៈចែកព្រះសហគមន៍ជាបីភូមិភាគ គឺកំពង់ចាម បាត់ដំបង និងភ្នំពេញ។ នៅអំឡុងទសវត្សរ៍៧០ ប្រទេសជួបសង្គ្រាម លោកអភិបាលបូជាចារ្យ និងគ្រិស្តបរិស័ទជាច្រើនត្រូវបានសម្លាប់។ នៅថ្ងៃទី ៤ មេសា ឆ្នាំ១៩៩០ ព្រះសហគមន៍បានទទួលច្បាប់អនុញ្ញាតឡើងវិញ។



Photo: P. Samphy

លោកស៊ី ទើរី

**បន្ទាប់ពីមានសង្គ្រាមស៊ីវិលជាច្រើនឆ្នាំ ប្រទេសកម្ពុជានៅសល់ផ្ទៃដីព្រៃឈើប្រមាណពី ៣៥% ទៅ៦០% និងផ្តល់ជាជម្រកដល់សត្វព្រៃដ៏កម្រៗ ដូចជាខ្លាដំបង ខ្លាឃ្មុំព្រះអាទិត្យ និងដំរីអាស៊ីជាដើម។ សម្រាប់លេខនេះ អ្នកនាំសារ បានជួបសម្ភាសន៍ជាមួយលោកស៊ី ទើរី មន្ត្រីគម្រោងនៃអង្គការសង្គ្រោះសត្វព្រៃកម្ពុជាស្តីអំពីកម្មវិធីអង្គការប្រឈមទៅនឹងគ្រោះវិនាសផុតពូជរបស់សត្វព្រៃដែលមានខ្លឹមសារដូចតទៅ:**

# សិក្សាអប់រំជួយជំរុញការអភិរក្សសត្វព្រៃ

**អ្នកនាំសារ:** តើកម្មវិធីសំខាន់របស់អង្គការសង្គ្រោះសត្វព្រៃមានអ្វីខ្លះ?

**លោកស៊ី ទើរី:** យើងមានកម្មវិធីអប់រំផ្សព្វ-ផ្សាយចំណេះដឹងបរិស្ថានដល់ប្រជាជន ដែលរស់នៅក្នុងតំបន់ព្រៃ និងប្រជាពលរដ្ឋគ្រប់រូប ដើម្បីឆ្លើយតបទៅនឹងការអភិរក្សសត្វព្រៃ ការការពារព្រៃឈើ ព្រមទាំងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានគង់វង្សយូរអង្វែង។

**អ្នកនាំសារ:** តើហេតុអ្វីបានជាអង្គការផ្តោតទៅលើការអប់រំផ្សព្វផ្សាយទៅវិញ?

**លោកស៊ី ទើរី:** យើងប្រកាន់កម្មវិធីនេះទី១ គឺដោយសារសព្វថ្ងៃនេះប្រជាជនយើងនៅមានការយល់ដឹងតិចទន្ទឹមនឹងតម្រូវការរបស់គាត់ច្រើន។ ទី២ នៅកម្ពុជា ក៏មិនទាន់មានការរៀបចំដកហូតយកផល ឬអនុផលព្រៃឈើ សត្វព្រៃឱ្យបានត្រឹមត្រូវនៅឡើយទេ។ ទី៣នោះ គឺច្បាប់របស់យើងមិនទាន់មានប្រសិទ្ធភាព ១០០% ក្នុងការគោរពទេ។ ដូច្នេះយើងមានតែអប់រំផ្សព្វផ្សាយទៅដល់ប្រជាជនដើម្បីឱ្យពួកគាត់ចូលរួមអភិរក្សធនធានធម្មជាតិ ដូចជាសត្វព្រៃជាដើម។ សូមឱ្យធ្វើការសម្គាល់បន្តិចថា ការអភិរក្សនេះ គឺមិនមែនមានន័យថា ហាមមិនឱ្យប្រើប្រាស់នោះទេ តែឱ្យប្រើប្រាស់ក្នុងបរិមាណមួយកំណត់ដើម្បីរក្សាធនធានឱ្យមានលំនឹង អាចរីកសាយភាយទៅមុខទៀត។

**អ្នកនាំសារ:** តើមានសត្វព្រៃកម្រៗអ្វីខ្លះដែលកំពុងរងការគំរាមកំហែងផុតពូជនៅកម្ពុជា?

**លោកស៊ី ទើរី:** ថនិកសត្វសំខាន់ៗ ដែលកំពុងតែទទួលការគំរាមកំហែងខ្លាំង ដូចជា ប្រភេទខ្លា ដំរី ទន្សោង ក្របីព្រៃ គោព្រៃ -ល- ពពួកថនិកសត្វទាំងនេះច្រើនចូលចិត្តរស់នៅក្នុងព្រៃស្រោងដែលមានដើមឈើខ្ពស់ៗ និងមានស្មៅ ឬរុក្ខជាតិនៅខាងក្រោមដែលជាចំណីរបស់ពួកវា។

**អ្នកនាំសារ:** តើសត្វព្រៃដែលទទួលការគំរាមកំហែងនេះបណ្តាលមកពីកត្តាអ្វីខ្លះ?

**លោកស៊ី ទើរី:** យើងឃើញថា ការបាត់បង់សត្វព្រៃ ទីមួយ គឺដោយសារតម្រូវការចាំបាច់នៅក្នុងគ្រួសាររបស់ប្រជាជន ដែលចាប់សត្វយកទៅធ្វើពិធីបុណ្យតាមទំនៀមទំលាប់។ ទីពីរ គឺជាតម្រូវការទីផ្សារ។ ឈ្មួញមកពីក្រៅតំបន់ទៅទាក់ទងជាមួយប្រជាជនផ្ទាល់ដើម្បីទិញសត្វ។ ចំណែកឯព្រៃឈើ ក៏ឈ្មួញទុច្ចរិតកាប់ដោយខុសច្បាប់យកទៅលក់។ បើព្រៃឈើថយចុះ សត្វព្រៃក៏ថយចុះព្រោះបាត់ជម្រក។ម្យ៉ាងវិញទៀតដោយកំណើនប្រជាជន ធ្វើឱ្យការសង់ផ្ទះលំនៅដ្ឋានកើនឡើង។ ពេលណាពួកគាត់ ឬក៏អ្នកណាផ្សេងៗ ធ្វើការរានដីព្រៃដើម្បីកាប់ឈើ និងយកដីទៅប្រើប្រាស់ វាក៏ធ្វើឱ្យចំនួនសត្វព្រៃត្រូវថយចុះផងដែរ។

**អ្នកនាំសារ:** តើអាជ្ញាធរមូលដ្ឋានគួរធ្វើដូចម្តេចដើម្បីឱ្យការអភិរក្សមានប្រសិទ្ធភាព?

**លោកស៊ី ទើរី:** អាជ្ញាធរត្រូវសហការជាមួយនឹងប្រជាជន ដើម្បីបង្ក្រាបបទល្មើសផ្សេងៗ នៅក្នុងតំបន់របស់គាត់ ដើម្បីឱ្យប្រជាជនមានជំនឿចិត្ត និងយល់ថា អាជ្ញាធរមានទំនួលខុសត្រូវ។

**អ្នកនាំសារ:** ប្រសិនសត្វព្រៃនៅគង់វង្ស តើវាផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គម?

**លោកស៊ី ទើរី:** នៅក្នុងធម្មជាតិ ជីវៈចម្រុះមានសារសំខាន់ណាស់។ព្រៃឈើ និងសត្វព្រៃពឹងពាក់គ្នាទៅវិញទៅមក។ បើសត្វព្រៃ នៅគង់វង្ស ពួកវាជួយសាយភាយគ្រាប់ពូជឱ្យព្រៃឈើរីតដុះលូតលាស់ល្អ។ ពេលមានព្រៃច្រើន អាកាសធាតុ និងរបបទឹកភ្លៀងក៏មានទៀងទាត់ ធ្វើឱ្យជីវភាពរស់នៅរបស់មនុស្សក៏បានប្រសើរ។ ម្យ៉ាងទៀត ព្រៃឈើ-សត្វព្រៃ គឺអាចទាក់ទាញចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរ ឱ្យទៅទស្សនា ដែលធ្វើឱ្យប្រជាជនអាចរកចំណូលបាន។ សេដ្ឋកិច្ចជាតិក៏រីកចម្រើនតាមរយៈទេសចរណ៍ធម្មជាតិ។

អត្ថបទដោយផាត សំភី



បណ្តុះបណ្តាលទំពាំងស្នងឬស្សីឱ្យចេះស្រលាញ់បរិស្ថាន និងសត្វព្រៃ

Photo: Save Cambodia's Wildlife

## ជីវៈចម្រុះជាអ្វី?

មានន័យថា ជាភាវៈរស់ប្រភេទខុសគ្នាជាច្រើនរស់នៅក្នុងតំបន់ណាមួយផ្សេងៗគ្នា។ ប្រភេទមួយៗ មានមុខនាទីមួយនៅក្នុងស្ថានប្រព័ន្ធ។ នៅលើផែនដីមានភាវៈរស់យ៉ាងតិចពី ៥-១០លាន ប្រភេទខុសៗគ្នា។

## អង្គការសង្គ្រោះសត្វព្រៃ

អង្គការនេះមានទីតាំងស្ថិតនៅគេហដ្ឋានលេខ ២៧២ ផ្លូវ ១០៧ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។ ទូរស័ព្ទ: ០២៣ ២១១ ២៦៣។ វេបសាយ: www.cambodiaswildlife.org



# អំពីឧទ្យានជាតិព្រះមុនីវង្ស ហៅ "ភ្នំបូកគោ"

**ឧទ្យាជាតិនេះត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ និងត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជានាថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។**



វិហារកាតូលិកដែលសល់ពីសម័យអាណានិគមបារាំងលើភ្នំបូកគោ

Photo: S. Metrey

ឧទ្យានជាតិភ្នំបូកគោ គឺជាតំបន់ការពារធម្ម-ជាតិមួយ ក្នុងចំណោមតំបន់ការពារ ទាំង២៣កន្លែងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ដោយមានផ្ទៃដី ១៤០ ០០០ ហិចតា ឧទ្យានជាតិនេះលាតសន្ធឹងលើខេត្តបួន នៅភាគខាងត្បូងប្រទេស គឺ ខេត្តកំពត កំពង់ស្ពឺ កោះកុង និងក្រុងព្រះសីហនុ។ នេះជាឧទ្យានជាតិដែលជាជម្រក និងជាទីអាស្រ័យ របស់ពួករុក្ខជាតិ និងសត្វព្រៃជាច្រើនប្រភេទ ហើយវាជាតំបន់ដែលប្រើប្រាស់ ជាប្រយោជន៍ច្រើនយ៉ាង ដូចជាការអភិរក្សធនធានជីវៈចម្រុះ ផ្តល់កន្លែងលំហែ និងជាតំបន់សិក្សាស្រាវជ្រាវ-ល-។

### ស្ថានភាពភូមិសាស្ត្រ

ឧទ្យានជាតិ ភ្នំបូកគោ ស្ថិតនៅភាគខាងត្បូងនៃជួរភ្នំក្រវាញ និងជួរភ្នំដំរីរមាល ដែលគ្របដណ្តប់ដោយភ្នំតូចៗជាច្រើន មានផ្ទៃខ្ពស់នៅទិសខាងជើង និងខាងកើត និងចំណោតនៅឯទិសខាងលិច និងទិសនិរតី ដែលវាងាយស្រួលក្នុងការចំណាត់ថ្នាក់ធ្វើជាឧទ្យានធម្មជាតិក្នុងការការពារ ពីការទន្ទ្រានផ្សេងៗ។ ស្ថានភាពផ្ទៃដី គឺមានកម្ពស់ពី១០ ទៅ១០៧៩ម៉ែត្រ ពីលើនីវ៉ូសមុទ្រ។ ក្នុងឧទ្យានជាតិ មានស្ទឹងឆ្លងកាត់មួយយ៉ាងសំខាន់គឺ ស្ទឹងទឹកឈូរ។

### អាកាសធាតុ

ស្ថិតក្នុងតំបន់ត្រូពិច ភ្នំបូកគោ គឺមានអាកាសធាតុម៉ូសុង ដែលមានរដូវពីរ ផ្សេងគ្នា គឺរដូវប្រាំងក្តៅចាប់ពីខែវិច្ឆិកា ដល់ខែឧសភា និងរដូវវស្សាជាក់ជាមួយនឹងភ្លៀងព្យុះ ពីខែ ឧសភា ដល់ខែតុលា។តំបន់នេះគឺមានខ្យល់ញឹកញាប់ និងកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំ ១៨១៣មម។ អាកាសធាតុប្រែប្រួលមធ្យមពី ១០អង្សា ពីខែកក្កដា ទៅដល់ ២១អង្សា ពេញមួយរយៈពេលប៉ុន្មានខែនៅសល់ក្នុងមួយឆ្នាំ។

### ស្ថានជីវៈចម្រុះ

នៅក្នុងឧទ្យានព្រះមុនីវង្ស ហៅថា ភ្នំបូកគោ មាន វត្តមានថនិកសត្វជាច្រើនប្រភេទ ដូចជា ដំរី ខ្លាដំបង ខ្លាផ្សេងៗ ខ្លាឃ្មុំសាមបា គោព្រៃ និងប្រភេទខ្លាឃ្មុំជាច្រើនទៀត ដែលកំពុងរស់រានមានជីវិត នៅក្នុងចំណោមក្រុម សត្វដែលគួរឱ្យចាប់អារម្មណ៍ គឺពពួកសត្វទោច។ សត្វស្លាបមានប្រហែលជាង ៣០០ប្រភេទ ដែលត្រូវបានគេធ្វើការរំពឹងថា មានវត្តមាន នៅទីនោះ។ ចំណែកប្រភេទសត្វដែលអាចរស់នៅលើទឹកផង និងលើគោកផង មានប្រមាណជា ៧ប្រភេទ ដែលត្រូវបានគេកំណត់ទុកចូលទៅក្នុងប្រភេទសត្វល្មូនផ្សេងៗគ្នា។ ...

# ...សួនអភិរក្សសត្វព្រៃ ភ្នំតាម៉ៅ

បើគេធ្វើដំណើរតាមដងផ្លូវជាតិលេខ២ ទៅទិសត្បូងរាជធានីភ្នំពេញចម្ងាយប្រហែល ៤០គម គេនឹងឃើញប៉ាណូធំមួយនៅខាងស្តាំដៃ ដែលមានគំនូរសត្វព្រៃផ្សេងៗ។ នេះគឺជាសញ្ញាច្រកចូលឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ភ្នំតាម៉ៅ។

សួនសត្វភ្នំតាម៉ៅស្ថិតនៅឃុំរំពង់ ស្រុកបាទី ខេត្តតាកែវ។ សួននេះបានបើកឱ្យភ្ញៀវចូលទស្សនាជាលើកដំបូងនាខែមេសា ឆ្នាំ១៩៩៥ ដោយស្ថិតនៅក្រោមការគ្រប់គ្រង នៃអាជ្ញាធររដ្ឋបាលព្រៃឈើរបស់ក្រសួងកសិកម្ម។ សព្វថ្ងៃនេះ នៅក្នុងសួនសត្វទាំងមូល មានសត្វព្រៃជាង ៨០ប្រភេទ នេះរាប់បញ្ចូលទាំងសត្វស្លាប ជាច្រើនប្រភេទ ថនិកសត្វ និងសត្វពពួកសត្វល្មូនផ្សេងៗ ទៀត។

ជាទូទៅសត្វទាំងនេះ គឺទទួលបានមកពីភ្នាក់ងារមានសមត្ថកិច្ច ដែលរឹបអូសយកបានមកពីឈ្មួញជួញដូរសត្វព្រៃខុសច្បាប់។ ចំណែកសត្វខ្លះទៀតគឺជាអំណោយរបស់សប្បុរសជននានា។

លោក ពិន លីវ៉ុន ជាអនុប្រធានសួនសត្វ ភ្នំតាម៉ៅ មានប្រសាសន៍ឱ្យដឹងថា គោលដៅក្នុងការបង្កើតឧទ្យាននេះឡើង មាន ៣ចំណុចសំខាន់ៗ ទីមួយ គឺក្រសួងកសិកម្មចង់ស្តារព្រៃឈើនៅតំបន់នេះឡើងវិញក្រោយពីបានទទួលរងការវិនាស ដោយសារសង្គ្រាម និងការកាប់បំផ្លាញ អស់រយៈពេលជាង២ទសវត្សរ៍។ ទីពីរ គឺក្រសួងចង់អភិរក្សសត្វព្រៃ ដែលស្ទើរតែជិតផុតពូជទៅហើយនោះ ឱ្យវាមានកំណើនឡើង ច្រើនមកវិញ ដើម្បីយកពួកវាទៅព្រលែងនៅក្នុងព្រៃធម្មជាតិដើមវិញ។ ចុងក្រោយ គឺបង្កើតការងារធ្វើ ឱ្យដល់ប្រជាជនក្នុងតំបន់ ពីព្រោះប្រជាជនដែលរស់នៅក្នុងភូមិជិតៗនេះ អាចមកធ្វើជាកម្មករ ឬក៏លក់នំចំណីជូនដល់ភ្ញៀវទេសចរបាន។

លោកពិន លីវ៉ុន បន្តថា ការលំបាកដ៏ធំមួយរបស់ឧទ្យានសួនសត្វ គឺបញ្ហាកង្វះខាតទឹកសម្រាប់ប្រើប្រាស់ ក៏ដូចជាសម្រាប់ឱ្យសត្វផឹក។ ជារៀងរាល់ឆ្នាំ សួនសត្វត្រូវស្តុកទុកនូវទឹកភ្លៀងនារដូវវស្សា ដើម្បីទុកប្រើប្រាស់នៅពេលខែប្រាំង។ ទោះបីជាមានការជីកអណ្តូង ឬបូមយកទឹកពីទន្លេបាទី មកប្រើប្រាស់ក្តី ក៏វិធីសាស្ត្រទាំងនេះនៅមិនទាន់ហុចលទ្ធផលឱ្យគួរជាទីពេញចិត្តនៅឡើយទេ។



Photo: P. Samphy

ខ្លាដំបងដែលចិញ្ចឹមថែរក្សាក្នុងសួនសត្វ

## លោកបូជាចារ្យអ៊ុន សុន: "ការលោភលន់ជាអំពើខុសពីព្រះហឫទ័យព្រះជាម្ចាស់"



Photo: L. Sovanna

លោកឪពុកអ៊ុន សុន

ព្រះជាម្ចាស់បង្កើតធម្មជាតិឡើងសម្រាប់ឱ្យមនុស្សធ្វើជាម្ចាស់លើរបស់ទាំងនោះ។ ដូច្នេះបើពួកគេទទួលបាន ត្រូវចេះថែរក្សា ដោយពុំត្រូវបំផ្លាញឡើយ ដូចជាយើងប្រើប្រាស់សត្វជាអាហារ ក៏យើងមិនត្រូវបំផ្លាញដោយគ្មានពិចារណាដែរ ទោះបីជាយើងមានសិទ្ធិលើពួកគេក៏ដោយ។

សព្វថ្ងៃនេះ សត្វព្រៃកាន់តែហិនហោចទៅៗមកពីខ្វះយល់ដឹង ការគ្រប់គ្រងគ្មានសណ្តាប់ធ្នាប់ អនាធិបតេយ្យ គ្មានការការពារ ដោយគិតតែពីប្រយោជន៍ខ្លួន និងសេចក្តីត្រូវការ។ នេះគឺជាចំនុចខ្សោយដែលធ្វើឱ្យសត្វព្រៃ និងសម្បត្តិធម្មជាតិត្រូវបានបាត់បង់។ បញ្ហានេះជាកាតព្វកិច្ចរបស់រដ្ឋ និងប្រជាពលរដ្ឋ ដែលត្រូវចូលរួមថែរក្សាសម្បត្តិរួមទាំងនេះ។

តើពួកគេគួរបញ្ឈប់ ឬធ្វើបន្ត? នេះអាស្រ័យទៅលើពួកគេផ្ទាល់។ ពួកគេត្រូវឈប់ បើគិតថា ធនធានទាំងនេះសំខាន់សម្រាប់ផ្តល់តម្លៃដល់ប្រទេសជាតិ។ ព្រះជាម្ចាស់បង្កើតមនុស្សលោកឱ្យរស់នៅលើលោកនេះទាំងអស់គ្នា ឱ្យមានទីជម្រក មានចំណីអាហារ តែបើមនុស្សបំផ្លាញ មនុស្សលោភលន់ ប្រើប្រាស់ទៅតាមអ្វីដែលខ្លួនចង់បាននោះ វាគឺជាអំពើដែលខុសពីព្រះហឫទ័យរបស់ព្រះជាម្ចាស់ហើយ។





គ្រិស្តបរិស័ទនៅព្រះសហគមន៍ចុងឃ្នៀសនៅខេត្តសៀមរាប មានជីវិតរស់នៅលើផ្ទៃបឹងទន្លេសាបដ៏ធំល្វឹងល្វើយ ទោះបីជីវភាពមានការលំបាកមែន ក៏បងប្អូននៅតែប្រកាន់ខ្ជាប់នូវជំនឿរបស់ខ្លួនយ៉ាងមុតមាំ និងរស់ប្រមូលផ្តុំគ្នាដូចជាគ្រួសារតែមួយ។

# ចុងឃ្នៀស: ព្រះសហគមន៍លើទឹក




Photo: P. Samphy

រស់នៅលើទឹកទាំងថ្ងៃទាំងយប់ព្រោះមិនដឹងទៅណា

ដោយយោលយោគទៅតាមចរន្តទឹករលកនៃបឹងទន្លេសាប ព្រះសហគមន៍ចុងឃ្នៀសមានព្រះវិហារមួយ មានរូបរាងជាអគារបណ្តែតទឹក ដែលមានដំបូលប្រក់សង្កសី និងមានទំហំប្រហែលជា ៦គុណ២១ម៉ែត្រ។ ព្រះវិហារត្រូវបានសាងសង់ឡើងនៅពីលើបំពង់ឫស្សីចងផ្អោបគ្នា ដូចជាក្បូន ដែលអាចទ្រ និងធ្វើឱ្យព្រះវិហារអណ្តែតនៅលើផ្ទៃទឹកបាន។

ព្រះសហគមន៍ចុងឃ្នៀស ឋិតនៅក្នុងភូមិទី៧ ឃុំចុងឃ្នៀស ស្រុកសៀមរាប ខេត្តសៀមរាប។ មកទល់សព្វថ្ងៃនេះ ព្រះសហគមន៍ មានគ្រិស្តបរិស័ទចំនួន ៩គ្រួសារ គឺខ្មែរ ១គ្រួសារ និងវៀតណាម ៨គ្រួសារ ដែលមានសមាជិកទាំងអស់ ជាង ៥០នាក់។ ប៉ុន្តែអ្នកដែលបានទទួលព្រះកាយរូច មានតែ ៧នាក់ គឺខ្មែរ ១នាក់ និងវៀតណាម ៦នាក់ ក្រៅពីនោះ សុទ្ធសឹងតែជាអ្នកដែលកំពុងស្វែងយល់។

លោក គង់ ប៊ុនថន ជាសមាជិកគណៈកម្មការព្រះសហគមន៍ចុងឃ្នៀស រៀបរាប់ថា នាបច្ចុប្បន្ននេះ ព្រះសហគមន៍ មានកម្មវិធីបង្រៀនភាសាខ្មែរ និងអង់គ្លេសដល់ក្មេងៗ ជនជាតិវៀតណាម។ ចំពោះភាសាខ្មែរ គឺបង្រៀនស្របតាមកម្មវិធីក្រសួងអប់រំ ប៉ុន្តែមានតែថ្នាក់ទី១ និងទី៣ ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ក្មេងៗ អាចរៀនបន្តនៅសាលារដ្ឋ ពេលដែលពួកគេរៀនចប់នៅទីនេះ។ លើសពីនេះ រៀងរាល់ថ្ងៃអាទិត្យ ព្រះសហគមន៍មានធ្វើបបរ ឱ្យក្មេងៗញ៉ាំ បន្ទាប់ពីពួកគេបានចូលរួមអភិបូជា និងទទួលការអប់រំជំនឿ។ ក្រៅពីការរៀបចំទាំងនេះ ព្រះសហគមន៍នៅមិនទាន់មានកម្មវិធីអ្វីថ្មីទេ។

ក្នុងព្រះសហគមន៍ចុងឃ្នៀសនេះ ភាគច្រើននៃគ្រិស្តបរិស័ទមានមុខរបរជាអ្នកនេសាទ ពោលគឺមាន ៨៥%។ ចំណែកឯ ១៥% ទៀត ប្រកបមុខរបរផ្សេងៗ ដូចជាលក់ដូរ របស់របរបន្តិចបន្តួច ធ្វើជាងឈើ ជាងធ្វើទូក ជាងផ្ទះ និងជាងម៉ាស៊ីន -ល-។ ជីវភាពរបស់គ្រិស្តបរិស័ទគឺមានសភាពយ៉ាប់យ៉ឺន។ មានបងប្អូន ១ភាគបីប៉ុណ្ណោះ ដែលធូរធាររស់នៅសមរម្យ និងមានផ្ទះបណ្តែត ក្រៅពីនេះ គឺរស់នៅលើទូកតូចៗ និងរកទទួលទានតែមួយឆ្អែតៗ ប៉ុណ្ណោះ។

លោកគង់ ប៊ុនថន បញ្ជាក់ថា: "ចំពោះបញ្ហាជីវភាព យើងមិនទាន់រកឃើញគន្លឹះណាដោះស្រាយនៅឡើយទេ។ យើងខ្វះដើមទុនដើម្បីយកទៅប្រកបមុខរបរ។ យើងមានបំណងអំពាវនាវដល់សប្បុរសជន ដើម្បីជួយព្រះសហគមន៍ ឱ្យមានសេរីភាពខាងសេដ្ឋកិច្ច។ ខ្ញុំយល់ដែរថា ប្រសិនបើយើងមានគម្រោងត្រឹមត្រូវនោះ គេប្រាកដជាជួយយើង"។

ចំណែកក្នុងជីវភាពប្រចាំថ្ងៃ លោកគង់ ប៊ុនថន រៀបរាប់ថា ការរស់នៅលើទឹកមិនមែនជាការងាយស្រួលប៉ុន្មានទេ ទាល់តែអ្នកមានទម្លាប់ ទើបអាចរស់នៅបាន។ ពេលខ្លះ មានជួបខ្យល់ព្យុះបក់ខ្លាំងៗ ដែលធ្វើឱ្យបងប្អូនគ្រិស្តបរិស័ទមានការភ័យខ្លាច និងធ្វើឱ្យព្រះវិហាររងការខូចខាត។ ជួនកាលមានការលំបាកក្នុងការជួបជុំគ្នា នៅពេលដែលទឹកឡើងចុះម្តងៗ ព្រោះបងប្អូនម្នាក់ៗ តែងអូសលំនៅឡើងចុះ មុនក្រោយគ្នាជានិច្ច ដែលជួនកាលធ្វើឱ្យគេស្ថិតនៅឃ្លាតពីគ្នាខ្លាំង។ សូមបញ្ជាក់ថា ជារៀងរាល់ឆ្នាំ មានតែពេលទឹកនៅហ្នឹងប៉ុណ្ណោះ ដែលបងប្អូនគ្រិស្តបរិស័ទ អាចនៅជួបជុំគ្នាបានស្រួល។ នៅក្នុងតំបន់ចុងឃ្នៀសនេះ ទឹកនៅហ្នឹង គឺចាប់ពី ខែកុម្ភៈ ដល់ខែមិថុនា។ ទឹកចាប់ផ្តើមឡើងពី ខែមិថុនា ដល់ចុង ខែតុលា ដែលធ្វើឱ្យបងប្អូនត្រូវអូសលំនៅឡើងតាម។ ទឹកចាប់ផ្តើមស្រកថយទៅវិញចាប់ពី ខែវិច្ឆិកា រហូតដល់ ខែកុម្ភៈ។

ផាត សំភី

## ប្រវត្តិរបស់ចុងឃ្នៀស

ព្រះសហគមន៍ចុងឃ្នៀស បានចាប់ផ្តើមដំណើរការតាំងពីខែមិថុនា ឆ្នាំ២០០១មក ដោយដំបូងមានគ្រិស្តបរិស័ទមួយក្រុមនៅទីនោះ ដែលប្រហែលជា ៥ គ្រួសារ។ ពួកគាត់មិនមានកន្លែងសម្រាប់ធ្វើការអធិដ្ឋាន ឬធ្វើអភិបូជា ដើម្បីពង្រឹងជំនឿរបស់ខ្លួនឡើយ ហើយក៏មិនស្គាល់ព្រះសហគមន៍នៅសៀមរាបដែរ។ ដោយឃើញដូច្នេះ លោកឪពុកទម្លាប់ សុផល បានផ្តួចផ្តើមគំនិតដោយទិញផ្ទះបណ្តែតមួយនាឆ្នាំ២០០១ និងជួសជុសកែលំអហើយរួចរាល់នៅឆ្នាំ២០០២ ដោយមានការចូលរួមពីគ្រិស្តបរិស័ទរស់នៅទីនោះស្រាប់។

# ស្វែងយល់អំពីព្រះសហគមន៍ទាំងអស់គ្នា

នៅពេលនេះ “អ្នកនាំសារ” សូមនាំបងប្អូនមកជួបជាមួយនឹងលោកបូជាចារ្យម៉ារីយូ ដើម្បីធ្វើការបកស្រាយចំពោះចម្ងល់របស់បងប្អូនលើចំនុចមួយចំនួនទាក់ទងទៅនឹងព្រះជាម្ចាស់ក៏ដូចជាព្រះសហគមន៍កាតូលិកដែលមានខ្លឹមសារដូចខាងក្រោម :



លោកបូជាចារ្យហ្គេហ្សិ ម៉ារីយ៉ូ ដែលឆ្លើយសំនួរទាក់ទងព្រះសហគមន៍

Photo: DR

**សំណួរ :** តើពាក្យថាស្លាប់ហើយរស់ឡើងវិញនៅក្នុងសាសនាកាតូលិកមានន័យដូចម្ដេច?

**លោកបូជាចារ្យម៉ារីយូ :** ពាក្យទាំង២នេះ ជាគ្រឹះមូលដ្ឋានមួយនៅក្នុងជំនឿរបស់យើង ដោយសារពាក្យទាំងពីរនេះវាបង្ហាញយើងឱ្យដឹងនូវចំនុចពីរសំខាន់គឺ ទី១ “ស្លាប់” បង្ហាញថា ព្រះយេស៊ូជាមនុស្សម្នាក់ដូចយើងទាំងអស់គ្នា ជាមនុស្សម្នាក់ ដែលទទួលមរណភាពដូចយើងដែរ។ ប្រសិនបើយើងគិតអំពីជីវិតរបស់ព្រះយេស៊ូ ឃើញថា ក្នុងរយៈពេល ៣៣ ឆ្នាំ ព្រះយេស៊ូរស់នៅតាមរបៀបធម្មតា ដូចជាមនុស្សយើងម្នាក់ៗដែរ។ ព្រះអង្គក៏ធ្វើការ ព្រះអង្គមានសេចក្ដីស្រលាញ់ចំពោះគេ ទ្រង់មានមិត្តភក្តិរៀននៅសាលាជាដើម។ នៅ ៣ ឆ្នាំចុងក្រោយ ព្រះយេស៊ូមានមុខងារពិសេស ដោយព្រះអង្គបានបង្រៀនឱ្យប្រព្រឹត្តអំពើល្អ ព្រះអង្គទេសនាច្រើន។ ដូចនេះយើងអាចនិយាយថា ការស្លាប់របស់ព្រះយេស៊ូជាភ័ស្តុតាងមួយបង្ហាញថា ព្រះយេស៊ូគឺជាមនុស្សម្នាក់ធម្មតាដូចជាយើងទាំងអស់គ្នាដែរ។ ចំណែកឯពាក្យថា “រស់ឡើងវិញ” ពាក្យនេះ បង្ហាញឱ្យយើងទាំងអស់គ្នាដឹងថា ព្រះយេស៊ូពិតជាព្រះជាម្ចាស់ ហើយព្រះអង្គជាមនុស្សធម្មតាដូចយើងដែរ ដោយសារព្រះអង្គទទួលមរណភាពដូចជាយើង។ ប៉ុន្តែព្រះយេស៊ូជាព្រះជាម្ចាស់ដ៏ពិតប្រាកដមែន ពីព្រោះព្រះអង្គបានរស់ឡើងវិញ។ ដូច្នេះយើងជឿលើព្រះយេស៊ូដោយសារព្រះអង្គមានព្រះជន្មរស់ឡើងវិញ ប៉ុន្តែប្រសិនបើ ព្រះយេស៊ូមិនមានព្រះជន្មរស់ឡើងវិញ យើងគ្រាន់តែទទួលថា ព្រះអង្គជាមនុស្សធម្មតាប៉ុណ្ណោះ ហើយប្រហែលជាយើងចាត់ទុកទ្រង់គ្រាន់តែជាគ្រូដ៏ល្អម្នាក់ តែមិនអាចចាត់ទុកថាលោកជាព្រះជាម្ចាស់បានទេ។ ដូច្នេះព្រះជន្មរស់ឡើងវិញនៃព្រះជាម្ចាស់គឺជាហេតុការណ៍មួយ ដែលធ្វើឱ្យព្រះយេស៊ូ ប្លែកពីអ្នកដទៃជាព្រះជាម្ចាស់ដ៏ពិតប្រាកដ និងជាមនុស្សយ៉ាងពិតប្រាកដ។ នេះជាលក្ខណៈពិសេសរបស់ព្រះយេស៊ូ។ ចំពោះយើង ដែលជាមនុស្សធម្មតាជឿថា ក្រោយពេលដែលយើងស្លាប់ យើងនឹងបានជីវិតរស់ឡើងវិញជាមួយព្រះយេស៊ូគ្រិស្ត នៅឯស្ថានបរមសុខជាមួយព្រះបិតាដែរ។ នៅក្នុងលក្ខណៈមួយថ្មីដែលពិសេសមែនទែនដោយសារនៅទីនោះមានសេចក្ដីស្រឡាញ់ មានសន្តិភាព និងការចេះគោរពគ្នាទៅវិញទៅមក ពិតមែនជាកន្លែងមួយដែលមិនមានការស្អប់គ្នា គ្មានអំពើបាប ហើយក៏គ្មានអំពើអាក្រក់សោះឡើយ។

យើងត្រូវគិតអំពីជីវិតរបស់ព្រះយេស៊ូ ពិតមែន ព្រះអង្គបានឈ្នះសេចក្ដីស្លាប់ ដែលនេះជាសេចក្ដីសង្ឃឹមសម្រាប់មនុស្សយើងម្នាក់ៗ។ ព្រះអង្គបានសន្យាថា យើងនឹងរស់ឡើងវិញជាមួយព្រះអង្គ នៅថ្ងៃចុងក្រោយដែរ។ នៅពេលដែលមានមិត្តភ័ក្តិ ឬបងប្អូនទទួលមរណភាព គឺយើងពិបាកចិត្ត យើងយំ ព្រោះការស្លាប់មិនមែនជាការស្រួល ប៉ុន្តែក្នុងនាមយើងជាគ្រិស្តបរិស័ទ យើងជឿថា ពិតមែនថា ព្រះយេស៊ូបានឈ្នះលើសេចក្ដីស្លាប់។ ហេតុដូចនេះហើយយើង សង្ឃឹមថា បងប្អូនរបស់យើង ដែលបានទទួលមរណភាពទៅហើយនោះ ក៏នឹងបានទទួលនូវជីវិត រស់ឡើងវិញ ជាមួយព្រះយេស៊ូដែរ។ ដូច្នេះយើងមានអំណរសប្បាយពិតប្រាកដមែន ដោយយើងដឹងថា ពួកគេបានរស់នៅជិតព្រះយេស៊ូហើយ។

មុំ គន្ធា

### ការបកស្រាយចម្ងល់

ប្រសិនបើប្រិយមិត្តអ្នកអាន “អ្នកនាំសារ” មានចម្ងល់ ឬសំណួរទាក់ទងនឹងព្រះសហគមន៍កាតូលិក ក៏ដូចជារឿងរ៉ាវ ដែលមិនទាន់យល់ច្បាស់អំពីព្រះជាម្ចាស់។ ប្រិយមិត្តអាចសរសេរជាសំណួរមកការិយាល័យអ្នកនាំសារ តាមរយៈលោកបូជាចារ្យដែលនៅជិតបំផុត ឬទូរស័ព្ទមកលេខ ០១៦ ៣២៦ ៧៣៧ ឬ ០១២ ៣៣៨ ៩៨៥។ យើងខ្ញុំបកស្រាយជូនដោយអញ្ជើញលោកបូជាចារ្យផ្សេងៗមកធ្វើការពន្យល់។





# ការចិញ្ចឹម និងថែទាំត្រី

ត្រីគឺជាអាហារមួយដ៏ល្អសម្រាប់ទ្រទ្រង់រាងកាយមនុស្ស និងវាក៏ងាយស្រួលក្នុងការស្វែងរកទិញនៅតាមទីផ្សារដែរ។ ត្រីជាសត្វធម្មតា ប៉ុន្តែចំពោះការចិញ្ចឹមគឺមិនមានការងាយស្រួលក្នុងការថែទាំប៉ុន្មានទេ ប្រសិនបើយើងមិនដឹងពីបច្ចេកទេសនោះ។ តើធ្វើយ៉ាងណាដើម្បីចិញ្ចឹមត្រីឱ្យទទួលបានទិន្នផលល្អ ?



ប្រភេទត្រីស្រកាដែលប្រជាកសិករខ្មែរយើងតែងនិយមចិញ្ចឹម

លោករាជ សុភាព ជាអនុបណ្ឌិតវារីវប្បកម្ម និងផលិតពូជត្រីនៃអង្គការសេដាកបានធ្វើការរៀបរាប់អំពីរបៀបក្នុងការចិញ្ចឹមត្រីដើម្បីឱ្យទទួលបានផលល្អ។

**ទីតាំង**

ដើម្បីចិញ្ចឹមត្រីបានធំធាត់ល្អ យើងត្រូវរើសទីតាំងអំណោយផល។ ការជីកស្រះជិតដើមឈើ ឬក៏ក្បែរតំបន់លិចទឹកពេកនឹងធ្វើឱ្យបាត់បង់ត្រីនៅពេលទឹកជន់។ ចំណែកម្លប់ ធ្វើឱ្យត្រីមិនអាចធំធាត់បានល្អដែរ។ ត្រីចិញ្ចឹមក្នុងស្រះ ឬក្នុងស្រែ វាមានលក្ខណៈល្អដូចគ្នា បើគេចេះរៀបចំស្រះឱ្យបានល្អនោះ។ ការចិញ្ចឹមត្រីក្នុងស្រែ ជួយកាត់បន្ថយស្មៅ ចកសារាយ និងជួយដល់ការលូតលាស់ស្រូវផងដែរ ហើយការផ្ដល់ចំណីមានចំនួនតិចជាងចិញ្ចឹមក្នុងស្រះ។ ត្រីយកចិញ្ចឹមក្នុងស្រះ មានទំហំពី ៤-៦ ហ៊ុន និងក្នុងស្រែទំហំ ៨-១២ ហ៊ុន។

**ការជីកស្រះ**

ស្រះត្រូវជីកបណ្ដោយថ្ងៃ ពីព្រោះអាចទទួលពន្លឺថ្ងៃបានយូរ ត្រូវជីករាងជាស្នូកជ្រូក ជៀសវាងបាក់ដី ទឹករាក់ និងមិនថ្លាល្អ។ ដើម្បីការពារទឹកស្រះ យើងធ្វើទំនប់ការពារនៅជុំវិញ ដើម្បីកុំឱ្យដីដែលយើងជីកដាក់ពីលើ ហូរចូលស្រះ ធ្វើឱ្យទឹកល្អក់។ យើងត្រូវដាក់ទៅតាមប្រភេទត្រី។ បើសិនត្រីស្រកា យើងត្រូវដាក់ពី ៣-៥ក្បាល ក្នុង ១ម៉ែត្រការ៉េ បើត្រីឥតស្រកាស ដាក់ពី ៨-១២ ឬ១៥ក្បាល (ត្រីប្រា) ចំណែកត្រីអណ្ដែង គឺដាក់ពី ១៥-២០ក្បាល នៅក្នុង ១ការ៉េ។

មុននឹងដាក់ត្រី ពិសេសដើមរដូវវស្សា យើងត្រូវបូមទឹក និងប្រមូលយកស្លឹកឈើ ឬកំទេចកំទី នៅក្នុងនោះ ចេញឱ្យអស់ ហើយបើបាតស្រះនោះសម្បូរទៅដោយជាតិភក់-ស្អុយ ត្រូវកាយវាចេញ រួចបាចកំបោរ (ស្រះចាស់អាចបាចកំបោរពី៥-៧គក ក្នុង ១០០ម៉ែត្រការ៉េ ចំណែកឯស្រះថ្មីអាចបាចលើសពី១០-១៥គក ដោយសារកំបោរ វាអាចជួយកាត់ទឹក កាត់មេរោគ និងធ្វើឱ្យត្រីមានការលូតលាស់ល្អ។

**ចំណី និងការថែទាំ**

ចំណីត្រីស្រកា ដែលប្រជាជនយើងតាមជនបទ ងាយស្រួលស្វែងរក គឺត្រកួន ចក កន្ទុំថេត ផ្ទី ស្រូវត្រាំ និងបន្លែផ្សេងៗយកមកហាន់តូចៗ លាយនឹងកន្ទក់ដាក់ឱ្យវាស៊ី។

បើត្រីនៅតូច ផ្ដល់ចំណី មួយថ្ងៃ ២-៣ដង។ បើវាមានទំហំ១២ហ៊ុនឡើង ២ដង ក្នុង១ថ្ងៃ ចាប់ពីម៉ោង ៨-៩ ព្រឹក និងល្ងាច ចន្លោះ ម៉ោង ៤-៦ ដែលកម្រិតទៅតាមប្រភេទត្រី។ ត្រីស្រកា ឱ្យ៣%នៃទំងន់ខ្លួន ឯត្រីអណ្ដែង ឬត្រីប្រា ឱ្យ៥%នៃទំនង់វា។ ការផ្ដល់ចំណីធម្មជាតិ និងចំណីនៅតាមផ្សារគឺវាល្អដូចគ្នា គ្រាន់តែចំណីបារ វាមានការចំណាយខ្ពស់ជាង។ ត្រីមិនស៊ីចំនី យើងអាចដឹងបានពេលព្រឹកព្រលឹម ដូចជា ត្រីហាមាត់ខ្លាំង បឺតយកខ្យល់អាកាសលើទឹក និងហែលជុំវិញស្រះ ពីព្រោះស្រះខ្វះអុកស៊ីសែន និងមានជាតិពុល។ ចំនុចមួយទៀត អាចបណ្ដាលមកពីគេដាក់ចំណីច្រើនពេក។

មុំ គន្ធា

### កន្លែងសិក្សា

លោកអ្នកចង់សិក្សាពីបច្ចេកទេសនៃការចិញ្ចឹមត្រីគ្រប់ប្រភេទ មាននៅមជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (ស៊ីដាក) ឬអញ្ជើញអ្នកជំនាញខាងវារីវប្បកម្ម និងផលិតកូនត្រីពូជទៅបង្រៀនដល់កន្លែងដោយគិតតម្លៃសមរម្យ។ សូមទំនាក់ទំនងលោករាជ សុភាព : ០១៦ ៦៣៦ ៨៧១។




សកម្មភាពប្រលែងកូនត្រីទៅក្នុងស្រះចិញ្ចឹម

Photos: CEDAC

## តើនាងតូចក្នុងរូបខាងក្រោមនេះកំពុងធ្វើអ្វី? សូមគូសភ្ជាប់ពីចំនុចលេខ ១ រហូតដល់លេខ ៤១ ប្រិយមិត្តនឹងដឹងជាក់ជាមិនខាន។





# ព្យាបាលការញៀនថ្នាំ

**ពេលថ្នាំញៀនជ្រាបចូលក្នុងខ្លួនយើងហើយ នោះអ្វីៗ ដែលជាទីស្រលាញ់របស់យើងនឹងរលាយជាមិនខាន។ តើធ្វើយ៉ាងណាទើបធ្វើឱ្យខ្លួនយើងក្លាយមកជាសភាពដើមវិញបាន?**

យោងតាមប្រសាសន៍របស់ លោកវេជ្ជបណ្ឌិត សុខ សេដ្ឋបុត្ត ព្យាបាលជំងឺផ្លូវចិត្ត និងញៀនថ្នាំនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងពីវិធីសាស្ត្រនៃការព្យាបាលអ្នកញៀនថ្នាំថា: "ការព្យាបាលអ្នកញៀនថ្នាំមាន ២របៀប គឺដោយការប្រើប្រាស់ថ្នាំពេទ្យ និងការព្យាបាលដោយចិត្តសាស្ត្រ"។ លោកបន្តថា ប្រភេទថ្នាំដែលប្រើនោះគឺជាប្រភេទថ្នាំផ្លូវចិត្ត ដែលប្រើតាមប្រព័ន្ធអន្តរជាតិ ដូចជាប្រភេទថ្នាំ ណឺរ៉ូអុបទិច ដែលមាន ២ប្រភេទ គឺប្រភេទ High potential (សម្រាប់អ្នកដែលប៉ះពាល់ផ្នែកវិញ្ញាណធ្ងន់ធ្ងរ) និង Low potential (សម្រាប់អ្នកដែលពុំដេកពួន និងមានអារម្មណ៍ក្តៅក្រហល់ក្រហាយ)។ ពេលព្យាបាល គឺត្រូវទៅជួបគ្រូពេទ្យដើម្បីឱ្យធ្វើការពិនិត្យចៀសវាងការប្រើប្រាស់ថ្នាំមុន ដោយមិនបានពិគ្រោះជាមួយពេទ្យដែលអាចនាំឱ្យជួបនូវផលពិបាក។ ចំពោះការព្យាបាល ដោយចិត្តសាស្ត្រ គឺយើងធ្វើការពន្យល់ណែនាំដោយស្តាប់នូវហេតុផលរបស់ពួកគេ និងថែមទាំងធ្វើការជជែកអំពីការគ្រោះថ្នាក់នៃថ្នាំញៀនទាំងអស់។ ការព្យាបាលទាំងនេះក៏តម្រូវឱ្យមានការទំនាក់ទំនងជាមួយគ្រួសារផងដែរ ដូចជាឪពុកម្តាយ ឬក៏អ្នកទទួលខុសត្រូវពួកគេដោយឱ្យធ្វើការឃ្លាំមើល ឬតាមដានអ្នកជំងឺ ឱ្យបានជាប់លាប់ក្នុងរយៈពេល ២សប្តាហ៍ ដំបូងនៃការព្យាបាល។

វិធីសាស្ត្រនៃការព្យាបាល មានប្រសិទ្ធភាពដូចគ្នា ហើយបើសិនជាប្រើវិធីសាស្ត្រទាំង២នេះ រួមបញ្ចូលគ្នានោះ គឺកាន់តែប្រសើរ គួបផ្សំនឹងការហាត់ប្រាណតាមកម្មវិធីត្រឹមត្រូវ និងផឹកថ្នាំតាមវេជ្ជបញ្ជាទៀតនោះ គឺរឹតតែល្អ។

ប្រសិទ្ធភាពនៃការព្យាបាលដោយប្រើថ្នាំ គឺអាស្រ័យលើអ្នកជំងឺ។ បើអ្នកជំងឺមានវ័យក្មេង គឺមានការលំបាកជាងអ្នកជំងឺវ័យចាស់ដែលមានការតាំងចិត្តល្អដើម្បីផ្តាច់ការញៀនថ្នាំ។

មុំ គន្ធា និងហ៊ូ សុខធារី



Photo: M. Kunthear

លោកវេជ្ជបណ្ឌិតសុខ សេដ្ឋបុត្ត ជំនាញព្យាបាលញៀនថ្នាំ

### កន្លែងពិគ្រោះ និងព្យាបាល

បើអ្នកចង់ផ្តាច់គ្រឿងញៀន ឬមានបញ្ហាផ្លូវចិត្ត អាចទៅទាក់ទងជាមួយវេជ្ជបណ្ឌិតជំនាញជំងឺទាំងនេះ។ ទូរស័ព្ទ: ០១២ ៨២៤ ០៥០ ឬ០១២ ៨៦៩ ២៦០។





# អ្នកព័ត៌មានវិទ្យា

**ការងារទាំងឡាយគឺមិនដូចគ្នាទេ ការងារខ្លះត្រូវប្រើដោយកម្លាំងកាយ និងខ្លះទៀតត្រូវប្រើគំនិត និងការច្នៃប្រឌិតច្រើនដូចជា ការងារអ្នកពត៌មានវិទ្យាជាដើម។ តើអ្នកព័ត៌មានវិទ្យាត្រូវធ្វើអ្វីខ្លះ?**



Photo: S. Metrey

កុំព្យូទ័រគឺជាឧបករណ៍ចាំបាច់បំផុតសម្រាប់អ្នកព័ត៌មានវិទ្យា

### ការងារ

ការងារអ្វីក៏ដោយ គឺតម្រូវឱ្យអ្នកធ្វើចាំបាច់ត្រូវតែសិក្សា ឱ្យចេះនូវមូលដ្ឋានគ្រឹះរបស់មុខវិជ្ជាការងារនោះ ឬក៏សញ្ញាណមួយចំនួនរបស់វាដើម្បីងាយស្រួលក្នុងការបំពេញការងារ។ កញ្ញាគង់ករុណា ជាអ្នករចនា និងសរសេរកូដនៃគម្រោងវេបសាយមួយដែលនាងបង្កើតជាក្រុមការងារដោយខ្លួនឯងផ្ទាល់ មានប្រសាសន៍ថា: "ដើម្បីក្លាយជាអ្នកព័ត៌មានវិទ្យាតម្រូវឱ្យយើងរៀននូវមុខវិជ្ជាសំខាន់ៗ គឺដូចជា គណិតវិទ្យារូបវិទ្យា ភាសាអង់គ្លេស និងគ្រឹះនៅលើផ្នែកកុំព្យូទ័រ។ ក្នុងចំណោមមុខវិជ្ជាទាំងនេះ អ្នកសិក្សាមានការលំបាក ឬងាយស្រួល គឺវាអាស្រ័យលើផ្នែកនីមួយៗ ឬទៅតាមអ្នករៀន។

### ផលលំបាក

កញ្ញាករុណាបានឱ្យដឹងទៀតថា ការងារជាអ្នកព័ត៌មានវិទ្យាគឺមានការលំបាកច្រើននៅពេលទើបចាប់ផ្តើមធ្វើការដំបូង ឬទើបបញ្ចប់ការសិក្សាថ្មីៗ។ ដូចនេះការងារចំពោះមុខតែងតែមានការពិបាក ចំពោះអ្នកព័ត៌មានវិទ្យា ដែលជាហេតុធ្វើឱ្យយើងត្រូវធ្វើការស្វះស្វែងរកអ្នកផ្សេងដើម្បីជួយ ឬក៏បំភ្លឺយើងជាដើម តែប្រសិនបើយើងបានចេញធ្វើការ យើងធ្លាប់បានអនុវត្តជាមួយអ្វីដែលយើងធ្លាប់ធ្វើហើយ នៅពេលនោះយើងអាចធ្វើការងារបានដោយងាយស្រួលជាងមុន។ ក្រុមហ៊ុនមួយៗចាំបាច់ ត្រូវតែមានអ្នកព័ត៌មានវិទ្យា ទោះបីក្រុមហ៊ុននោះមិនទទួលបម្រើសេវាកម្មសរសេរកម្មវិធី ឬអ្វីផ្សេងក៏ដោយ។ ហេតុដូច្នេះគឺដើម្បីសម្រួលការងារសម្រាប់បុគ្គលិកធ្វើការក្នុងក្រុមហ៊ុន ទោះបីជាការងារ ក្នុងការបើកប្រាក់ខែដល់បុគ្គលិកក៏ដោយ។ ការងារស្ទើរតែទាំងអស់ត្រូវពឹងផ្អែកលើអ្នកព័ត៌មានវិទ្យា។

### ប្រាក់កម្រៃ

ប្រាក់បៀវត្សរ៍ដែលអ្នកព័ត៌មានវិទ្យាភាគច្រើនទទួល តែងមានប្រៀបលើការងារផ្សេងៗ។ អ្នកជួសជុលកុំព្យូទ័រធម្មតាក៏អាចរកចំណូលបានច្រើនជាងគេដែរ។ ម្យ៉ាងវិញទៀតអ្នកព័ត៌មានវិទ្យា នៅពេលរៀនចប់ ភាគច្រើន គេឱ្យតម្លៃច្រើនជាងការងារដទៃ ពីព្រោះវាមានការលំបាកច្រើនជាពិសេសការងារនេះ អ្នកធ្វើការនេះត្រូវប្រើខួរក្បាលច្រើន។

មុំ គន្ធា

### ជំនាញអ្នកព័ត៌មានវិទ្យា

អ្នកបង្កើតកម្មវិធី និងសរសេរប្រព័ន្ធគ្រប់គ្រងទិន្នន័យ អ្នកគ្រប់គ្រង និងបង្កើតវេបសាយ អ្នកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ អ្នកជួសជុលកម្មវិធី និងកុំព្យូទ័រ...។ មុខវិជ្ជានេះមានបង្រៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ទូរស័ព្ទ: ០១២ ៧៥៤ ៣៤៤។ មានការរៀនជាអាហារូបករណ៍ និងបង់លុយចំនួន ៤៥០$ ក្នុង១ឆ្នាំ ដោយសិក្សាក្នុងរយៈពេល ៤ឆ្នាំ។

# សុភា: "នេះគឺជាសមត្ថភាពខ្ញុំរួមផ្សំនឹងការប្រទានពរពីព្រះជាម្ចាស់"



Photo: L. Sovanna

កញ្ញារ៉ូន សុភា អ្នករបាំនៃព្រះសហគមន៍តាហែន

**ក្រៅពីការសិក្សា នាងត្រូវចំណាយពេល ២ម៉ោងរាល់យប់ដើម្បីហាត់របាំ។ កញ្ញារ៉ូន សុភា អាយុ១៧ឆ្នាំ អ្នករបាំព្រះសហគមន៍តាហែន ភូមិភាគបាត់ដំបង។**

---

ក្រោមសម្លៀកបំពាក់អាវពណ៌ ស្លាទុំ សំពត់ចងក្បិនពណ៌ឈាមជ្រូក វង់ភក្ត្រមូលក្រឡង់ បីដូចព្រះច័ន្ទពេញវង់ រួមដោយស្នាមញញឹមជានិច្ចលើផ្ទៃមុខ កញ្ញារ៉ូន សុភា បានលើកដៃដ៏ស្រទន់ និងកាច់ចង្កេះ យ៉ាងស្រស់បំព្រង សេរាំនៅចំពោះមុខមហាជនទាំងចាស់ទាំងក្មេងដោយភាពក្លាហាន។ សម្លេងទះដៃកងរំពង បានបន្លឺឡើងក្រោយពេលដែលទស្សនីយភាពដ៏ល្អនេះបានបញ្ចប់។

ក្នុងកាយវិការអង្គុយដាក់ដៃលើភ្លៅយ៉ាងសុភាពរាបសា កញ្ញា ដ៏ស្រស់សោភារូបនេះ និយាយឱ្យដឹងថា: "ការហាត់រាំរបាំនេះមានការពិបាកច្រើនដោយសារវាជាលើកដំបូងរបស់ខ្ញុំដែលខ្ញុំមិនធ្លាប់បានឃើញ ផ្តួបផ្សំនិងគ្រូស្តីបន្ទោស និងត្រូវរំពាត់ច្រើនផងដែរ"។ ដោយយកដៃច្បូតសក់ យុវនារីមានសប្បុរសណ្ដែកបាយរូបនេះ បានបន្តថា នាងគ្មានបំណងក្លាយជាអ្នករាំរបាំទេ ប៉ុន្តែថៃដន្យនៅពេលនាងកំពុងរៀនអប់រំជំនឿ គ្រូរបស់នាងបានជ្រើសរើសនាងដើម្បីបង្ហាត់របាំ។ សុភា បានចូលហាត់ រៀនរាំរបាំនេះអំឡុងឆ្នាំ២០០១ មកម្ល៉េះ។ កញ្ញា រាងតូចច្រឡឹងរូបនេះ បានបន្ថែមទៀតថា រហូតមកទល់បច្ចុប្បន្ននេះ នាងអាចរាំបានរបាំជាច្រើនរហូតដល់ ១៥-១៦ក្បាច់ ដែលមានដូចជា របាំជូនពរ គោះត្រឡោក ច្រូតស្រូវ ព្រះនាងម៉ារីឱ! ព្រះបិតា និងក្លោកប៉ៃលិន-ល-។

សុភាមិនត្រឹមតែចេញសម្តែងតាមព្រះសហគមន៍នានានៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក្រុមរបាំរបស់នាងក៏បានចេញសម្តែងនៅក្រៅប្រទេសផងដែរ ដូចជាប្រទេសអេស្ប៉ាញជាដើម។ សុភា បង្ហាញអំពីចំណាប់អារម្មណ៍របស់នាង ចំពោះការសម្តែង នៅទីនោះដែរថា: "ខ្ញុំមានការសប្បាយរីករាយ និងរំភើបជាខ្លាំងពេលដែលខ្ញុំ និងមិត្តភក្តិឯទៀតជាតំណាងឱ្យព្រះសហគមន៍កាតូលិក នៅកម្ពុជា បានសម្តែងរបាំប្រពៃណីខ្លួននៅចំពោះមុខភ្ញៀវអន្តរជាតិដ៏ច្រើន"។ កញ្ញា មានមោទនភាពចំពោះខ្លួនឯងយ៉ាងខ្លាំងដោយសារនាងចេះរាំរបាំប្រពៃណីខ្មែរជាច្រើន មិនតែប៉ុណ្ណោះ នាងក៏អាចនឹងក្លាយទៅជាគ្រូបង្ហាត់របាំឱ្យដល់ក្មេងៗ ជំនាន់ក្រោយៗទៀតផង។ "នេះគឺជាសមត្ថភាពខ្ញុំ ផ្តួបផ្សំនឹងការប្រទានពរពីព្រះជាម្ចាស់ផងដែរ"។

"ខ្ញុំចង់រៀននៅសាលាវិចិត្រសិល្បៈ និងចង់ក្លាយទៅជាអ្នករាំរបាំអប្សរាដ៏ល្បីម្នាក់" នេះគឺជាសម្តីដ៏មុះមុត របស់អ្នករបាំវ័យក្មេងយើង។ ប៉ុន្តែនាងព្រួយបារម្ភ ដោយសារនាងមិនមែនជាសិស្សរៀនសាលាវិចិត្រសិល្បៈ។ នេះគឺជាការពិបាកសម្រាប់នាង។ ទោះបីការសម្តែងរបស់នាង នៅមានភាពខ្វះខាតក៏ដោយ តែនាងនៅតែមានទឹកចិត្តជានិច្ច ដោយសារ មានអ្នកជាទីស្រលាញ់របស់នាង នៅលើកទឹកចិត្តនាងជានិច្ច គឺដូចជា លោកបូជាចារ្យ គណៈកម្មការ និងគ្រួសារជាដើម។

មុំ គន្ធា

## ព្រឹត្តិការណ៍នឹងមាន!

- នៅដើមខែកក្កដា នេះ: ព្រះសហគមន៍កំពង់ចាមនឹងរៀបចំសមាគមសហការគ្នា ដើម្បីសន្និបាតសម្រាប់គ្រិស្តបរិស័ទកាតូលិកនៅខេត្តកំពង់ចាម។
- ថ្ងៃទី០២ កក្កដា: ខួបតែងតាំងមុខងារជាអភិបាលលើកទី៦ របស់លោកគីកេនៃព្រះសហគមន៍ភូមិភាគបាត់ដំបង។
- ថ្ងៃទី០២ កក្កដា: នៅព្រះសហគមន៍ក្រុងកំពង់សោម មានរៀបចំពិធីបើកឱ្យប្រើប្រាស់សាលាថ្មីនូវព្រះវិហារចាស់ដែលបានចាប់ជួសជុលតាំងពីដើមឆ្នាំ។
- ថ្ងៃទី១១-១៤ កក្កដា: មហាសន្និបាតមនុស្សពេញវ័យនៅកម្ពុជា ១១០នាក់ នៅព្រះវិហារផ្សារតូច លើប្រធានបទពីរគឺ ខួប៤៥០ឆ្នាំ នៃព្រះសហគមន៍កាតូ-លិកនៅកម្ពុជា និងប្រវត្តិព្រះសហគមន៍ជាចលនាជាក់ស្តែងរបស់ព្រះបន្ទូល។
- ថ្ងៃទី២២-២៣ កក្កដា: សំណាក់ធម៌របស់ក្រុមអេម៉ានូអែល ដែលមានយុវជនចូលរួមចំនួន ៣០នាក់ នៅជុំនបូស្តូទឹកថ្លា នៅក្រោមប្រធានបទ "ការត្រាស់ហៅរបស់ព្រះជាម្ចាស់"។
- ក្នុងអាទិត្យទី៤ នៃខែកក្កដា: យុវជនមកពី ប្រទេសអេស្ប៉ាញនឹងធ្វើការរួមជាមួយយុវជនកម្ពុជានៅបាត់ដំបងដើម្បីជួយក្មេងៗ រើសសំរាមនៅក្នុងខេត្តនេះ។
- ថ្ងៃទី៧-១១ សីហា: សិក្ខាសាលារបស់អង្គការការ៉ូល និងសេដ្ឋា នៅព្រះសហគមន៍កំពង់ចាម ដែលមានយុវជនចំនួន ៤០នាក់ចូលរួម។
- ថ្ងៃទី១៣-១៧ សីហា: ដំណើរទស្សនកិច្ចរបស់យុវជនជនជាតិកូរ៉េ មកពីហុងកុង ៤០នាក់ នៅព្រះសហគមន៍ស្លូងដើម្បីស្គាល់ព្រះសហគមន៍នៅកម្ពុជា។

ការិយាល័យផ្សព្វផ្សាយព័ត៌មានព្រះសហគមន៍កាតូលិក ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax: (855) 23 224 120 E-mail: csc@catholiccambodia.org & Website: www.catholiccambodia.org
អភិបាលគ្រប់គ្រង: លោកអភិបាល អេមីល ដេតម្ប អគ្គនាយក: លោកបូជាចារ្យ ហៃរណាន់ ពីនីយ៉ា